# អង្គការពលកម្មអន្តរជាតិ

## របាយការណ៍

## សិក្ខាសាលាសម្ពោធគំរោងអភិវឌ្ឍសិទ្ធិជនជាតិដើម

## ភាគតិចនៅកម្ពុជា




ភ្នំពេញ, ថ្ងៃទី 5-6 ខែ ឧសភា ឆ្នាំ2005

# មាតិកា

*សេចក្តីផ្តើម*...................................................................................................... 4

*គោលបំណង*...................................................................................................... 5

*វិធីសាស្ត្រ*...................................................................................................... 5

*ការសន្និដ្ឋាន និង អនុសាសន៍របស់សិក្ខាសាលា*.................................................... 7

ដីធ្លី ...................................................................................................... 7

ព្រៃឈើ សត្វព្រៃ និងជលផល...................................................................... 8

វប្បធម៌ប្រពៃណី...................................................................................... 8

សុខភាព ...................................................................................................... 9

ការអប់រំ និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ.......................................................... 9

***ថ្ងៃទី១: ការពិភាក្សាដោយមានការសំរបសំរួលក្នុងចំណោមអ្នកតំណាងជនជាតិដើមភាគតិច***.. 10

សេចក្តីផ្តើម ...................................................................................................... 10

សេចក្តីថ្លែងការណ៍របស់ជនជាតិដើមភាគតិចនិងប្រជាជនកុលសម្ព័ន្ធ............................ 10

ការពិភាក្សាតាមក្រុមនិងលទ្ធផល ...................................................................... 11

ការបង្ហាញរបស់ក្រុម ...................................................................................... 11

***ថ្ងៃទី២: ការសម្ពោធគំរោងនិងការចែករំលែកបទពិសោធន៍របស់អ្នកពាក់ព័ន្ធពហុភាគី*** ........................ 19

សេចក្តីផ្តើម...................................................................................................... 19

សន្ទរកថាស្វាគមន៍ដោយ Ms Ginette Forgues...................................................... 19

សុន្ទរកថាបើកដោយឯកឧត្តម **បណ្ឌិត ម៉ែន ដារ៉េត**............................................... 20

អង្គការពលកម្មអន្តរជាតិនិងជនជាតិដើមភាគតិចនៅកម្ពុជាដោយ Ms Birgitte Feiring................. 23
ទស្សនៈរួមអំពីគំរោងជនជាតិដើមភាគតិចនៅកម្ពុជារបស់ ILO ដោយលោក សេក សោភ័ណ............ 24
ការបង្ហាញអនុសាសន៍របស់ជនជាតិដើមភាគតិច...................................................................... 26
នាយកដ្ឋានអភិវឌ្ឍជនជាតិភាគតិច ( DEMD) ដោយវេជ្ជបណ្ឌិត សុត សឿង ................................ 27
ជនជាតិដើមភាគតិចនិងការកាត់បន្ថយភាពក្រីក្រដោយ Mrs Kristina Chhim ............................. 29
ការពិភាក្សាក្នុងសម័យប្រជុំពេញអង្គ.......................................................................................... 30
ការបង្ហាញរបស់ក្រុម ..................................................................................................... 36
ដីធ្លី ........................................................................................................ 36
ព្រៃឈើ សត្វព្រៃ និងជលផល.......................................................................................... 38
វប្បធម៌ និងប្រពៃណី................................................................................................... 39
សុខភាព ...................................................................................................................... 41
ការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ .................................................................... 43
សុន្ទរកថាបិទដោយ Ms Birgitte Feiring ............................................................................ 44
សុន្ទរកថាបិទដោយ **ឯកឧត្តម សុស ម៉ុសសុន** ................................................................. 45

## ឧបសម្ព័ន្ធ

# បញ្ជីពាក្យកាត់ខ្លី

| | |
|---|---|
| **CAS** | *មជ្ឈមណ្ឌលសំរាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់* |
| **CLEC** | *មណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍* |
| **CLJR** | *ក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងតុលាការ* |
| **COM** | *ទីស្តីការគណៈរដ្ឋមន្ត្រី* |
| **CTA** | *ប្រធានទីប្រឹក្សាបច្ចេកទេស* |
| **DEMD** | *នាយកដ្ឋានអភិវឌ្ឍជនជាតិភាគតិច* |
| **ILO** | *អង្គការពលកម្មអន្តរជាតិ* |
| **ITP** | *ជនជាតិដើមភាគតិចនិងប្រជាជនកុលសម្ព័ន្ធ* |
| **IMC** | *គណៈកម្មាធិការអន្តរក្រសួងដើម្បីអភិវឌ្ឍប្រជាជនតំបន់ភ្នំ* |
| **MRD** | *ក្រសួងអភិវឌ្ឍជនបទ* |
| **MEYS** | *ក្រសួងអប់រំ យុវជន និងកីឡា* |
| **MAFF** | *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* |
| **MOE** | *ក្រសួងបរិស្ថាន* |
| **MOI** | *ក្រសួងមហាផ្ទៃ* |
| **MLMUPC** | *ក្រសួងគ្រប់គ្រងដែនដី នគូរបនីយកម្ម និងសំណង់* |
| **MIME** | *ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល* |
| **NPC** | *អ្នកសំរបសំរួលគំរោងថ្នាក់ជាតិ* |
| **NPRS** | *យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ* |
| **PRO 169** | *គំរោងដើម្បីជំរុញគោលនយោបាយអំពីជនជាតិដើមភាគតិច និងប្រជាជនកុលសម្ព័ន្ធរបស់ ILO* |
| **PLG** | *ភាពជាដៃគូសំរាប់អភិបាលកិច្ចមូលដ្ឋាន* |
| **PLUP** | *ផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម* |
| **SRO** | *ការិយាល័យអនុតំបន់* |
| **UNESCO** | *អង្គការសហប្រជាជាតិសំរាប់ការអប់រំ វិទ្យាសាស្រ្តនិងវប្បធម៌* |
| **UNDP** | *កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ* |
| **UNICEF** | មូលនិធិសំរាប់កុមាររបស់អង្គការសហប្រជាជាតិ |

# សេចក្តីផ្តើម

សិក្ខាសាលាដើម្បីសម្ភោធគំរោង "អភិវឌ្ឍសិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជា" របស់ ILO បានប្រារព្ធ ធ្វើឡើងនៅ ថ្ងៃទី 5-6 ខែ ឧសភា ឆ្នាំ 2005 នៅសណ្ឋាគារភ្នំពេញ ។ គំរោងនេះ មានគោលបំណងកែលំអរគោលនយោបាយ និងច្បាប់ដែលពាក់ព័ន្ធជនជាតិដើមភាគតិច និងប្រជាជនកុលសម្ព័ន្ធនៅកម្ពុជា និងដើម្បីពង្រឹងអង្គការ តំណាងជនជាតិដើមភាគតិចនិងប្រជាជនកុលសម្ព័ន្ធផ្ទាល់ឱ្យដើរតួនាទីកាន់តែសកម្មថែមទៀត ក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្ត និងការអភិវឌ្ឍន៍។ គំរោងរួមមានដៃគូមកពីរដ្ឋាភិបាល សង្គមស៊ីវិលជនជាតិដើមភាគតិច និងប្រ ជាជនកុលសម្ព័ន្ធ។

នៅក្នុងសិក្ខាសាលា មានអ្នកចូលរួមចំនួន 66 នាក់ដែលមកពីអង្គការ និងក្រុមនានាដែលពាក់ព័ន្ធក្នុងការអនុវត្តន៍គោលនយោបាយពាក់ព័ន្ធនិងជនជាតិដើមភាគតិច និងប្រជាជនកុលសម្ព័ន្ធ ។ ក្នុងចំណោមអ្នកចូលរួមទាំងអស់មានអ្នកតំណាងជនជាតិដើមភាគតិចចំនួន 27 នាក់មកពីខេត្តចំនួន 14 តំណាងឱ្យ 10 ក្រុមផ្សេងគ្នាក្នុងនោះរួមមានៈ ជនជាតិគួយ ៨នាក់ ស្អៀង 1 នាក់ ព័រ ៤នាក់ ព្រៅ 2នាក់ ជង 2 នាក់ ទំពួន 2 នាក់ ចារ៉ាយ 1 នាក់ គ្រឹង 1 នាក់ ស្ទួយ 2 នាក់ និង ព្នង 4 នាក់ ។ អ្នកចូលរួមដ៏ទៃទៀត ជាមន្ត្រីរដ្ឋាភិបាលមកពីក្រសួងអភិវឌ្ឍជនបទ (MRD) ទីស្តីការគណៈរដ្ឋមន្ត្រី (COM) ក្រុមប្រឹក្សាកំណែទំរង់ផ្លូវច្បាប់និងតុលាការ (CLJR) គណៈកម្មាធិការជាតិដើម្បីប្រជាជននិងការអភិវឌ្ឍន៍ នាយកដ្ឋានសង្គមស៊ីវិល NGOs និងការងារសិទ្ធិមនុស្ស (មកពី COM) ក្រសួងអប់រំ យុវជននិងកីឡា (MEYS) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ក្រសួងបរិស្ថាន (MOE) ក្រសួង គ្រប់គ្រងដែនដីនគរូបនីយកម្មនិងសំណង់ (MLMUPC) រដ្ឋបាលព្រៃឈើ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) និងអ្នកតំណាងមកពីរដ្ឋបាលថ្នាក់ខេត្តជាច្រើននាក់ ។ អ្នកចូលរួមឯទៀតមកពីអង្គការសង្គមស៊ីវិល អង្គការអន្តរជាតិ និង ម្ចាស់ជំនួយទ្វេភាគីនិងពហុភាគី ។ ឯកឧត្តម **ប៉ែន ដារ៉េត** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងអ្នកតំណាង ~ឡើ មកពីទីក្រុង ហ្សឺណែវនិងបាងកក បានធ្វើជាអធិបតីក្នុងពិធីបើកអង្គសិក្ខាសាលានោះ។

អ្នកសំរបសំរួលគំរោងថ្នាក់ជាតិ (NPC) សំរាប់គំរោង ~ឡើ បានចូលកាន់មុខតំណែងរបស់ខ្លួន នៅថ្ងៃទី 11 មេសា ឆ្នាំ 2005 ហើយសិក្ខាសាលាសម្ភោធគំរោងនេះគឺជាជំហានដំបូង ក្នុងការអនុវត្តន៍ គំរោង ។ សិក្ខា សាលានេះ គឺជាព្រឹត្តិការណ៍បង្ហាញគំរោងជាក់លាក់ដែលផ្សព្វផ្សាយពតិមានអំពីគំរោង និងគោលបំណងនៃ គំរោងដល់អ្នកពាក់ព័ន្ធ និងអង្គការជាដៃគូ ដើម្បីឱ្យពួកគេបានដឹងអំពីអ្វីដែលបានធ្វើ និងកំពុងធ្វើក្នុងវិស័យ ច្បាប់និងគោលនយោបាយដែល ពាក់ព័ន្ធជនជាតិដើមភាគតិច និងប្រជាជនកុលសម្ព័ន្ធ។ សិក្ខាសាលាបាន ប្រារព្ធធ្វើឡើង ដើម្បីវាយតំលៃតំរូវការជាក់លាក់សំរាប់ការបណ្តុះបណ្តាលនិងការណែនាំគោលនយោបាយ និងដើម្បីពិភាក្សាអំពីរបៀប ដែលអង្គការផ្សេងៗអាចធ្វើការងារទាំងអស់គ្នា ដើម្បី

អនុវត្តសមាសភាព ផ្សេងៗរបស់គំរោង ។ ក្រៅពីផ្សព្វផ្សាយពត៌មានជូនដល់អ្នកចូលរួមសិក្ខាសាលានេះ គឺជាជំហានទីមួយ ក្នុងដំណើរការបង្កើតភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធទាំងអស់ ហើយអនុញ្ញាត្តិអោយអង្គការទាំងឡាយ ចូលរួមយ៉ាងសកម្មក្នុងការអនុវត្តន៏គំរោង។

## គោលបំណង

គោលបំណងរួមរបស់គំរោងក្នុងកម្ពុជា គឺការបង្កើតច្បាប់និងគោលនយោបាយជាតិដែលរួមបញ្ចូលសិទ្ធិតំរូវការនិង អាទិភាពរបស់ជនជាតិដើមភាគតិច និងប្រជាជនកុលសម្ព័ន្ធនៅកម្ពុជានិងការកសាងសមត្ថភាពដើម្បីអនុវត្ត ។

គោលបំណងរួមរបស់សិក្ខាសាលា គឺដើម្បីរួមចំណែកក្នុងការបង្កើតយុទ្ធសាស្រ្តអនុវត្តគំរោង ។ គោលបំណងជាបន្ទាន់ របស់សិក្ខាសាលាមានដូចខាងក្រោម :

1. ដេម្បីផ្សព្វផ្សាយពត៌មានអំពីគោលបំណងនៃគំរោងដល់អ្នកពាក់ព័ន្ធ
2. ដើម្បីរៀបចំអ្នកអនុវត្ត និងសកម្មភាពបច្ចុប្បន្នក្នុងវិស័យនៃបញ្ហាជនជាតិដើមភាគតិចនៅថ្នាក់ខេត្តនិងថ្នាក់មូលដ្ឋាន
3. ដើម្បីវាយតំលៃគម្លាតនិងតំរូវការដែលគំរោងរបស់ ILO អាចដោះស្រាយបាននៅថ្នាក់មូលដ្ឋានថ្នាក់ខេត្ត និងថ្នាក់ជាតិ និងកំណត់ការផ្សាភ្ជាប់ក៏រិតខុសគ្នាទាំងនេះទៅនិងអន្តរាគមន៏
4. បង្កើតអនុសាសន៏អំពីយុទ្ធសាស្រ្តដើម្បីអនុវត្តគំរោង។

## វិធីសាស្រ្ត

សិក្ខាសាលាបានរួមបញ្ចូលដោយវិធីសាស្រ្តដូចមានខាងក្រោម :

- ការបង្ហាញភាពពាក់ព័ន្ធចំពោះគោលបំណងនៃគំរោង
- ការពិភាក្សាតាមក្រុម ដោយមានការសំរបសំរួលដោយផ្អែកលើការបែងចែកអ្នកចូលរួមស្របតាមភូមិ
- សាស្រ្ត ( ថ្ងៃទីមួយ) និងប្រធានបទជាអាទិភាព ( ថ្ងៃទីពីរ)
- សម័យប្រជុំពេញអង្គដើម្បីពិភាក្សាបញ្ហាសំខាន់ៗ ការសន្និដ្ឋាននិងអនុសាសន៏នៃសិក្ខាសាលា ។

## ការសន្និដ្ឋាននិងអនុសាសន៍នៃសិក្ខាសាលា

សិក្ខាសាលាដើម្បីសម្ពោធគំរោងអភិវឌ្ឍសិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជា របស់ ILO បានប្រារព្ធឡើងនៅថ្ងៃទី 5-6 ខែ ឧសភា ឆ្នាំ 2005 នៅសណ្ឋាគារភ្នំពេញ។ អ្នកតំណាងចំនួន 66 នាក់មកពីអង្គការ និងក្រុមជាច្រើនបានចូលរួមក្នុងសិក្ខាសាលានេះ ។ ក្នុងចំណោមអ្នកចូលរួមទាំងអស់មាន 27 នាក់ជាជនជាតិដើមភាគតិច ។

ថ្ងៃទីមួយនៃសិក្ខាសាលាជនជាតិដើមភាគតិច បានពិភាក្សាគ្នា តាមក្រុមដោយមានការសំរបសំរួលរួច ហើយមានការបង្ហាញលទ្ធផល ។ គោលបំណងនៃការពិភាក្សាគឺដើម្បីរកបញ្ហារបស់ពួកគេ និងកំណត់អាទិភាពបញ្ហាទាំងនេះ ដោយអនុលោមតាមទស្សនះរបស់ពួកគេផ្ទាល់ ក្នុងក្របខ័ណ្ឌនៃគំរោង ILO ។ គេបានរកឃើញបញ្ហាខាងក្រោមថា ជាបញ្ហាសំខាន់ៗ :

1- ដីធ្លី
2- ព្រៃឈើ
3- ច្បាប់អំពីប្រពៃណី ទំនៀមទំលាប់និងវប្បធម៌
4- សុខភាព
5- ការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ

ថ្ងៃទីពីរជាថ្ងៃសិក្ខាសាលាសំរាប់អ្នកពាក់ព័ន្ធជាពហុភា គឺដោយមានការចូលរួមពី អ្នកតំណាងជនជាតិដើមភាគតិច ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ NGOs អង្គការអន្តរជាតិ និងម្ចាស់ជំនួយទ្វេភាគី និងពហុភាគី ។ ការបង្ហាញអំពីអាទិភាពដែលបានរកឃើញនៅថ្ងៃទីមួយ ការបង្ហាញអំពីគំរោងនិងទិដ្ឋភាពផ្សេងៗ នៃគោលនយោបាយពាក់ព័ន្ធជនជាតិដើមភាគតិចនៅកម្ពុជា បានផ្តល់ពត៌មានជាលំអិតដល់សម័យប្រជុំពេញអង្គ និងក្រុមពិភាក្ស ា។ បន្ទាប់ពីការបង្ហាញទាំងនោះរួចមក មានការពិភាក្សាតាមក្រុមលើប្រធានបទនៃបញ្ហាសំខាន់ៗ ដែលបានកំណត់ថាជាអាទិភាពនៅក្នុងថ្ងៃទីមួយ ។ ខាងក្រោមនេះជាអនុសាសន៍ ដែលជាលទ្ធផលពីក្រុមពិភាក្សា និង សម័យប្រជុំពេញអង្គ :

## ដីធ្លី

- ផ្តល់ការគាំទ្រ និងបច្ចេកវិជ្ជាចាំបាច់ដល់ការរៀបចំផែនទីដីធ្លី ។
- ផ្តល់ធនធានសំរាប់ការអនុវត្តន៍អនុក្រិត្យអំពីការចុះកម្មសិទ្ធិដីធ្លីថ្នាក់ឃុំ ។
- ធានានូវភាពស៊ីសង្វាក់គ្នានៃច្បាប់ពាក់ព័ន្ធ ។

- អាជ្ញាធរគួរទទួលស្គាល់សហគមន៍ ITP ជាបណ្តោះអាសន្ន មុនពេលដែលសហគមន៍នេះ ត្រូវបានចុះបញ្ជី ។
- ILO គួរចូលរួមក្នុងការរៀបចំច្បាប់បញ្ញត្តិដែលពាក់ព័ន្ធ និងការចុះបញ្ជីសហគមន៍ ។
- ធានាថា ITPs បានចូលរួមក្នុងគំរោងអភិវឌ្ឍទាំងអស់ ។
- ផ្តល់បុគ្គលិកជំនួយការផ្លូវច្បាប់ ។
- ផ្សព្វផ្សាយពតិមាន ផ្តល់ការបណ្តុះបណ្តាលនិងកសាងសមត្ថភាព ។
- ធានាថាការធ្វើសម្បទានសេដ្ឋកិច្ចអាចផ្តល់ឱ្យបានដោយមានការព្រមព្រៀងដោយសេរី ជាមុនពី ITPs
- ធានាថាត្រូវតែមានការវាយតំលៃពីផលប៉ះពាល់បរិស្ថាននិងសង្គម ។
- គោរពប្រពៃណីរបស់ ITPs និងទីកន្លែងគោរពបូជា ។
- សំរបសំរួលការបង្កើតយន្តការទទួលពាក្យបណ្តឹង ។
- បញ្ចូលផែនការប្រើប្រាស់ដីធ្លីក្នុងឃុំទៅក្នុងផែនការអភិវឌ្ឍឃុំ ។
- ជួយបង្កលក្ខណៈងាយស្រួលដល់ ITPs ដើម្បីឱ្យចេះគ្រប់គ្រងសហគមន៍របស់ខ្លួន ។

## ព្រៃឈើ សត្វព្រៃ និងជលផល

- ផ្តល់ការគាំទ្រជាមូលនិធិសំរាប់គំរោងតូចៗដែលធ្វើការងារផ្ទាល់ជាមួយសហគមន៍ ITPs
- បង្កើតក្រុមពិគ្រោះយោបល់នៅថ្នាក់មូលដ្ឋាន ថ្នាក់ខេត្តនិងថ្នាក់ជាតិ ។
- ផ្សព្វផ្សាយច្បាប់ដែលពាក់ព័ន្ធសហគមន៍មូលដ្ឋាន
- ផ្តល់វគ្គបណ្តុះបណ្តាលអំពីច្បាប់ដែលពាក់ព័ន្ធសហគមន៍ ITPs ។
- ពង្រឹងការអនុវត្តន៍ច្បាប់ ទទួលស្គាល់ស្ថាប័នជំនាញ ។
- គាំទ្ររដ្ឋបាលព្រៃឈើក្នុងការទទួលស្គាល់សហគមន៍និងព្រៃឈើនិងជួយព្រាងអនុក្រិត្យ ដើម្បីឱ្យបទ
- បញ្ញត្តិដែលមានស្រាប់អាចប្រតិបត្តិបាន ។

## វប្បធម៌និងប្រពៃណី

- បង្កើតកម្មវិធីត្បាញរវៃ ។
- ជំរុញភាសាជនជាតិដើមភាគតិច ។
- សំរបសំរួលការទទួលស្គាល់អាជ្ញាធរប្រពៃណីនិងដំណោះស្រាយជម្លោះ ។
- ផ្តល់ការបណ្តុះបណ្តាលដល់អាជ្ញាធរប្រពៃណី ។
- សំរបសំរួលការបណ្តុះបណ្តាលអំពីសន្ទានកម្មនិងការផ្សះផ្សារ ។
- ការពារកុំឱ្យមានការទន្ទ្រានដីធ្លីពីសំណាក់អ្នកខាងក្រៅ ។

- ការពារកុំឱ្យអ្នកខាងក្រៅមកតាំងទីលំនៅ ។
- ជំរុញការផលិតឧបករណ៍តន្ត្រី ។
- លើកកំពស់ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋានអំពីសិទ្ធិនិងប្រពៃណីរបស់ជនជាតិដើមភាគតិច ។
- រដ្ឋាភិបាលគួរទទួលស្គាល់និងគោរពជំនឿរបស់ជនជាតិដើមភាគតិច ។
- ធ្វើការស្រាវជ្រាវអំពីប្រវត្តិសាស្ត្រនៃជំនឿ ។

## សុខភាព

- សំរបសំរួលការផ្តល់មន្ទីរពេទ្យ ការបណ្តុះបណ្តាលនិងសំភារៈសមរម្យ ។
- ផ្តល់សេវាសុខភាពដោយឥតគិតថ្លៃដល់ជនក្រីក្រ ។
- កសាងផ្លូវលំជនបទដើម្បីឱ្យទទួលបានច្រើនជាងមុន ។
- ជីកអណ្តូងនិងស្រះឱ្យច្រើនថែមទៀត ។
- ផ្តល់ថ្នាំកម្ចាត់ជម្ងឺគ្រុនចាញ់ ។
- បង្កើនការផ្តល់មុង ។
- ផ្តល់ជំនួយដល់ភូមិនានាដែលមិនទាន់បានចុះបញ្ជី ។
- ក្រសួងសុខាភិបាលគួរពង្រឹងក្រមសីលធម៌សំរាប់គ្រូពេទ្យ ។
- សំរបសំរួលឱ្យ ITPs មានតំណាងរបស់ខ្លួនក្នុងគណៈកម្មាធិការមណ្ឌលសុខភាព ។
- ក្រសួងសុខាភិបាលគួរផ្តល់ការបណ្តុះបណ្តាលបន្ថែមដល់គ្រូពេទ្យបុរាណ ។
- គាំទ្រការរៀបចំឯកសារអំពីការអនុវត្តន៍សុខភាពតាមបែបបុរាណ ។
- សំរបសំរួលការបង្កើតបណ្តាញការងាររបស់គ្រូពេទ្យបុរាណដើម្បីផ្លាស់ប្តូរបទពិសោធន៍ ។

## ការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ

- បង្កើតអក្សរសំរាប់ភាសារបស់ ITP ។
- រៀបចំកម្មវិធីសិក្សាដោយមានការចូលរួមពី ITPs ។
- បណ្តុះបណ្តាលគ្រូបង្រៀនពីរភាសា ។
- ជំរុញការអប់រំពីរភាសាដោយសហការជាមួយប្រជាជនវ័យចាស់អាជ្ញាធរមូលដ្ឋាននិងសង្គមស៊ីវិល ។
- បង្កើតបណ្ណាគារចល័ត ។
- ផ្តល់ការបណ្តុះបណ្តាលអំពីបច្ចេកវិជ្ជានិងជំនាញកសិកម្ម ។
- គាំទ្រការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ដើម្បីផ្តល់កិត្តិយសដល់ការពិគ្រោះយោបល់ដែលនាំឱ្យទទួលបានអនុសាសន៍ទាំងនេះ គំរោងរបស់ ILO ចង់ដោះស្រាយអាទិភាពមួយ ក្នុងចំណោមអាទិភាពទាំងឡាយដែលរកឃើញ ដោយជនជាតិដើមភាគតិចខ្លួនឯងផ្ទាល់ និង បញ្ចូលអនុសាសន៍នានារបស់សិក្ខាសាលាទៅក្នុងផែនការសកម្មភាពរបស់គំរោង ។ ប៉ុន្តែគំរោងនឹងត្រូវការកិច្ចពិគ្រោះយោបល់ច្រើនទៀត ដើម្បីកំណត់ទំហំភូមិសាស្ត្រនៃគំរោង និងដើម្បីរកកន្លែងដែលបានកំណត់ជាក់លាក់ ក្នុងប្រធានបទដែលការចូលរួមរបស់ ILO នឹងបន្ថែមតំលៃយ៉ាងពិតប្រាកដ ។

ឈរលើមូលដ្ឋាននៃអនុសាសន៍ពីសិក្ខាសាលានេះ ផែនការសកម្មភាពមួយនឹងត្រូវបានព្រាងឡើងហើយនឹងត្រូវចែកជូន អ្នកចូលរួមទាំងអស់ ដើម្បីផ្តល់ពតិមានត្រឡប់ចំពោះគំរោងអំពីរបៀបបញ្ចូលអនុសាសន៍នានា ។ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពសំរាប់អង្គការជនជាតិដើមភាគតិច ក៏ដូចជាស្ថាប័នរដ្ឋាភិបាលនៅកំរិតផ្សេងៗ នឹងជាមធ្យោបាយយ៉ាងសំខាន់ដើម្បីជំរុញឱ្យមានសម្លេងជនជាតិ ដើមភាគតិចនិងការតំណាងដោយខ្លួនឯង និងដើម្បីលុបបំបាត់គម្លាតក្នុងការអនុវត្តន៍ច្បាប់ដែលមានស្រាប់ ។ ការបណ្តុះបណ្តាលគ្រូឧទ្ទេសសំរាប់ជនជាតិដើមភាគតិច នឹងត្រូវបានធ្វើឡើងក្នុងភាពជាដៃគូជាមួយ NGOs ជាច្រើនហើយនឹងផ្តោតលើក្រុមគោលដៅចំនួនពីរ ជាពិសេសគឺ អាជ្ញាធរប្រពៃណីនិងយុវជនជាតិដើមភាគតិច ដែលអាចធ្វើជាទីប្រឹក្សាផ្លូវច្បាប់ចំពោះអាជ្ញាធរប្រពៃណី ដោយគាំទ្រកិច្ចប្រឹងប្រែងរបស់ពួកគេ ។ ការបណ្តុះបណ្តាលនេះ នឹងត្រូវរៀបចំឡើងដោយឈរលើមូលដ្ឋានការវាយតំលៃ តំរូវការសមស្របជាវប្បធម៌ ។ ការផ្តោតជាសំខាន់សំរាប់ការកសាងសមត្ថភាពដល់ដៃគូរបស់រដ្ឋាភិបាល ដែលជាកំរិតមូលដ្ឋាននិងមន្ត្រីដែលបានជ្រើសរើសពីរដ្ឋាភិបាល ។

យន្តការសំរាប់ការផ្សព្វផ្សាយដ៏មានប្រសិទ្ធិភាព នៃពតិមានពាក់ព័ន្ធ ជាពិសេសចំពោះសហគមន៍ជនជាតិដើមភាគតិច នឹងត្រូវបានបង្កើតឡើងដើម្បីឱ្យអ្នកពាក់ព័ន្ធប្រកាន់ខ្ជាប់តាមគណនីភាពរបស់ ILO ។ ILO ធ្វើប្រតិបត្តិការតាមការសន្មត់ថា គំរោងនឹងដំណើរការដោយមានទស្សនះវិស័យរយៈពេលវែងបន្ទាប់ពីរយៈពេលមួយឆ្នាំដំបូងរួចហើយ ។

## ថ្ងៃទីមួយ ៖ ការពិភាក្សាដោយមានការសំរបសំរួលក្នុងចំណោមអ្នកតំណាងជនជាតិដើមភាគតិច

### សេចក្តីផ្តើម

ដើម្បីពង្រឹងការចូលរួមរបស់ជនជាតិដើមភាគតិច នៅថ្ងៃទីមួយ (5ឧសភា) នៃសិក្ខាសាលាបានរៀបចំធ្វើការពិភាក្សា និង ពិភាក្សាតាមក្រុមដោយមានការសំរបសំរួលក្នុងចំណោមជនជាតិដើមភាគតិច រួចបន្ទាប់មកមានការបង្ហាញលទ្ធផល ។ គោលបំណងរួមនៃថ្ងៃទីមួយគឺការពិគ្រោះយោបល់ជាមួយ ITP ដើម្បីរកបញ្ហារបស់ពួកគេ រួចហើយកំណត់អាទិភាពបញ្ហាទាំងនេះដោយអនុលោមតាមទស្សនៈរបស់ពួកគេផ្ទាល់ក្នុងក្របខ័ណ្ឌការងារនៃគំរោង របស់ ILO ។

លោកសេក សោភ័ណ ( NPC ) បានបើកសិក្ខាសាលា ។ លោកបានស្វាគមន៍ និងថ្លែងអំណរគុណអ្នកចូលរួមទាំងអស់ ដែលបានអញ្ជើញមកចូលរួម ថ្វីបើពួកគាត់មានការរវល់ការងារក្នុងសហគមន៍ក៏ ដោយ ។ លោកសេក សោភ័ណ បានពន្យល់ពីគោលបំណងសិក្ខាសាលា ដែលយកចិត្តទុកដាក់ស្តាប់អ្នកតំណាងជនជាតិដើមភាគតិច ដើម្បីប្រមូលផ្តុំទស្សនៈពួកគេពីបញ្ហាផ្សេងៗ អាទិភាពនានាដើម្បីការអភិវឌ្ឍន៍ និងអំពីគំនិតដែល ILO អាចរួមចំណែកដោះ ស្រាយបញ្ហាទាំងនេះ ។

### សេចក្តីថ្លែងការណ៍របស់ជនជាតិដើមភាគតិចនិងប្រជាជនកុលសម្ព័ន្ធ

បន្ទាប់ពីសុន្ទរកថាស្វាគមន៍រួចមក អ្នកចូលរួមទាំងអស់បានណែនាំខ្លួន (ឈ្មោះខេត្តសមាជិកភាពក្នុងក្រុម ) និងបង្ហាញពីបញ្ហាសំខាន់បំផុតរបស់ពួកគេ។ ពួកគេបានចំណាយពេលកន្លះថ្ងៃ ដើម្បីពិភាក្សាផ្តោតលើសេចក្តីថ្លែងការណ៍របស់ ITPs អំពីបញ្ហាក្នុងសហគមន៍របស់ខ្លួន ។ គ្រប់សហគមន៍ ITP ទាំងអស់ លើកលែងតែសហគមន៍មួយប៉ុណ្ណោះ បានជូនពត៌មានថាបញ្ហាពាក់ព័ន្ធដីធ្លីជាបញ្ហាអាទិភាព ។ បញ្ហាដែលពាក់ព័ន្ធដីធ្លីនោះ រួមមានការទន្ទ្រានដីធ្លី ការចូលកាន់កាប់ដីធ្លី កង្វះខាតចំណេះដឹងអំពីសិទ្ធិ ការលក់ដីធ្លីមានតំលៃទាបជាងតំលៃទីផ្សារដែលបណ្តាលមកពីការគាបសង្កត់ ឬកង្វះខាតចំណេះដឹង កង្វះខាត ជំនួយពីអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរខេត្ត ការកាប់ព្រៃឈើ មិនមានការចេញកម្មសិទ្ធិដីធ្លីថ្នាក់ឃុំ និងកង្វះខាតចំណេះដឹងអំពីនិតិវិធីដែលពាក់ព័ន្ធ ។ នៅក្នុងសេចក្តីថ្លែងការណ៍របស់ ITP ក៏មានលើកឡើងអំពីបញ្ហាសាសនាប្រពៃណីដូនតា វប្បធម៌ កង្វះខាតភាពចល័ត ការភ័យខ្លាច ការអប់រំនិងសុខ ភាព ។ ស្ត្រីជនជាតិដើមភាគតិចដែលបានចូលរួមបានបញ្ចេញមតិយ៉ាងសកម្ម និងថែងច្បាស់លាស់ក្នុងសេចក្តីថ្លែងការណ៍ ។ អង្គប្រជុំបានធ្វើឡើងជាភាសាខ្មែរ ហើយជូនកាលជាភាសាជនជាតិដើមភាគតិចដោយមានការជួយបកប្រែភាសាពីមិត្តភ័ក្រ្ត ។

## ការពិភាក្សាតាមក្រុមនិងលទ្ធផលនៃការពិភាក្សា

បន្ទាប់ពីការសំរាកកាហ្វេ អ្នកចូលរួមទាំងអស់បានរៀបចំជាបីក្រុម ដោយឈរលើមូលដ្ឋានទីតាំងភូមិសាស្រ្ត ដើម្បីពិភាក្សាបញ្ហាសំខាន់ៗ ដែលសហគមន៍របស់ពួកគេកំពុងជួបប្រទះ និងដើម្បីកំណត់អាទិភាពបញ្ហាទាំងនេះ រួចហើយបង្កើតអនុសាសន៍ឱ្យ ILO និងអ្នកពាក់ព័ន្ធឯទៀត ។ អ្នកតំណាងមកពីអង្គការ NGO Forum of Cambodia, CLEC និងអង្គការអភិរក្សសត្វព្រៃ (Wildlife Conservation Society ) បានសំរបសំរួលការ ពិភាក្សាតាមក្រុមទាំងនោះ ។



## ការបង្ហាញរបស់ក្រុម

បន្ទាប់ពីសំរាកអាហារថ្ងៃត្រង់ មានការបញ្ចាំងឈុតវីដេអូខ្លីៗ ចំនួន 3 រឿងដែលពាក់ព័ន្ធបញ្ហាដីធ្លី ព្រៃឈើ និង ទន្លេក្នុងខេត្តរតនគីរីរួចហើយអ្នកចូលរួមបានពិភាក្សាគ្នា ។ បន្ទាប់ពីការពិភាក្សា ការពិភាក្សាតាមក្រុមបានបន្តទៀត ។ នៅពេលល្ងាច អ្នកបង្ហាញដែលត្រូវបានក្រុមតែងតាំងបានឡើងបង្ហាញនូវលទ្ធផលសំខាន់ៗ ។ តារាងខាងក្រោម ជាការសង្ខេបការបង្ហាញទាំងនេះ ។

| ក្រុម | បញ្ហា | សកម្មភាពអាទិភាព | អនុសាសន៍ |
|---|---|---|---|
| ២ | ១- ដីធ្លី<br>- លក់ ទិញ ដូរ<br>- អ្នកមានអំណាចកាន់កាប់<br>- ក្រុមហ៊ុនសម្បទានដី<br>- អ្នកមកពីខាងក្រៅ<br>- ទំនាស់ដីកេរ្តិ៍ដូនតា<br>២- កសិកម្ម<br>- ខ្វះបច្ចេកទេសចិញ្ចឹមសត្វ<br>- ខ្វះដីដែលមានជីជាតិ<br>- ខ្វះពូជស្រូវ បន្លែ សត្វ<br>- គ្រោះរាំងស្ងួត<br>៣- អប់រំ<br>- ខ្វះចំណេះដឹង (អាន សរសេរ និងផ្សព្វផ្សាយ)<br>- ខ្វះសាលារៀន<br>- ខ្វះគ្រូបង្រៀន<br>- ត្រូវការការពង្រឹងសមត្ថភាព / បច្ចេកទេស<br>៤- វប្បធម៌ | ១- ដីធ្លី<br>២- ព្រៃឈើ សត្វព្រៃ ជលផល<br>៣- វប្បធម៌ ប្រពៃណី<br>៤- សិទ្ធិ<br>៥- សុខភាព ជីវភាព កសិកម្ម | - ការអប់រំផ្សព្វផ្សាយចំណេះដឹង<br>- សិទ្ធិក្នុងការគ្រប់គ្រង<br>- ការចុះបញ្ជីដីធ្លីសមូហភាព<br>- ពង្រឹងការអនុវត្តន៍ច្បាប់<br>- មានច្បាប់ អនុក្រិត្យទទួលស្គាល់សិទ្ធិ គ្រប់គ្រង របស់ជនជាតិដើមភាគតិច<br>---<br>ក្រុម ៣<br>- អនុសាសន៍<br>- ជុំរុញឱ្យអ្នកពាក់ព័ន្ធចូលរួមបញ្ចេញយោបល់ ដើម្បីរៀបចំច្បាប់លក្ខខន្តិកៈរបស់សហគមន៍ គោលនយោបាយរបស់ជនជាតិដើមភាគតិច<br>- អង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធចូលរួម រៀបចំចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច ឱ្យបានឆាប់<br>- លើកស្ទួយវប្បធម៌ជនជាតិដើមភាគតិច ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល និង GNOs |

| | | | |
|---|---|---|---|
| | - មិនមានការគោរពវប្បធិមពីអ្នកចំណូលថ្មី<br>- បាត់បង់ប្រពៃណី<br>- ការហូរចូលនូវវប្បធមិពីក្រៅ (វីដេអូ)<br>- សីលធមិ (នាំកូនម្រុំរត់)<br>- ក្មេងមិនគោរពចាស់ទុំ<br>៥- សុខភាព<br>- ខ្វះថវិកាបង់សេវា<br>- ខ្វះមណ្ឌលសុខភាព<br>- ខ្វះពេទ្យ (បុគ្គលិក)<br>- ខ្វះថ្នាំពេទ្យ<br>- ខ្វះការអប់រំផ្នែកសុខភាព<br>- ខ្វះខាតប្រភពទឹកស្អាត<br>- ទំនប់យ៉ារី,,,,,(វ៉ារី) ប៉ះពាល់សុខភាព<br>- ការប្រើប្រាស់ថ្នាំបាញ់ស្មៅប៉ះពាល់សុខភាព<br>៦- ជីវភាព<br>- ភាពក្រីក្រ<br>- បាត់បង់អនុផលព្រៃឈើ<br>- គ្រោះធម្មជាតិ | ក្រុម ៣<br>- អាទិភាព<br>- សិទ្ធិចាស់ស្រុក សម្រេចិត្ត<br>- ដីធ្លី<br>- ប្រពៃណីទំនៀមទំលាប់ សាសនា<br>- សិទ្ធិ អំណាច<br>- ទាមទារការគាំទ្រពីរដ្ឋអំណាច<br>- ការគ្រប់គ្រងធនធានធម្មជាតិ ការប្រើប្រាស់<br>- បង្កើតមុខរបរ<br>- ការអប់រំ ផ្សព្វផ្សាយ សុខភាព កសិកម្ម អភិវឌ្ឍន៍ចំរុះ និង ភាសា<br>- ដំណោះស្រាយតាមប្រពៃណី | - ការពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិចមុននឹងសម្រេចកសាង អភិវឌ្ឍន៍<br>- ជួយពង្រឹងនិងគាំទ្រសិទ្ធិរបស់ជនជាតិដើមភាគតិច<br>- គោរពសិទ្ធិ មតិយោបល់ និងឱ្យតម្លៃមតិក្នុងការសម្រេចចិត្ត<br>- រាជរដ្ឋាភិបាលគួរផ្ទេរសិទ្ធិតាមបែបវិមជ្ឈការដល់សហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងធនធានធម្មជាតិ<br>- អាជ្ញាធរផ្តល់សិទ្ធិអំណាចផ្នែកប្រពៃណីដល់ជនជាតិដើមភាគតិច<br>- ពង្រឹងច្បាប់<br>- ជួយប្រពៃណីដូនតារបស់ជនចាតិដើមភាគតិច<br>- ឱ្យចាស់ស្រុកចាស់ទុំមានសិទ្ធិក្នុងការសម្រេច |

| | | | |
|---|---|---|---|
| | - ខ្វះការអភិវឌ្ឍន៍គ្រប់ទីកន្លែង<br>៧- សត្វព្រៃ<br>- ការបរបាញ់ដោយប្រើកាំភ្លើង<br>- ការបរបាញ់សត្វព្រៃសម្រាប់លក់<br>៨- ព្រៃឈើ<br>- អ្នកមានអំណាច់ចូលមកកាប់ឈើ ព្រៃតម<br>- ការកាប់ព្រៃយកដីពីអ្នកមានអំណាច<br>- បុគ្គលខ្លះក្នុងសហគមន៍នាំអ្នកខាងក្រៅចូលកាប់ឈើ<br>៩- ជលផល<br>- ផលប៉ះពាល់ពីទំនប់យ៉ាលី<br>- មានការបូម ឆក់ នេសាទខុសច្បាប់<br>-----------------------------------<br>- ព្រៃឈើ<br>- ដីធ្លី<br>- ដីស្រែកសិកម្មថយចុះ<br>- ប្រពៃណី វប្បធម៌<br>- សិទ្ធិជនជាតិដើមភាគតិច<br>- បាត់មុខរបរតាមប្រពៃណី | | |

| | | | |
|---|---|---|---|
| ៣ | - សុខភាព-ឱសថ<br>- ការអប់រំ<br>- កាត់ក្តី<br>- សិទ្ធិអំណាច<br>- ការគាំទ្រ<br>- ការគ្រប់គ្រងភាសា<br>- ការសម្រេចចិត្តពីអាជ្ញាធរ<br>- ដំណោះស្រាយតាមប្រពៃណី<br>- ពុករលួយ<br>- ការគ្រប់គ្រងធនធានធម្មជាតិ<br>- ការប្រើប្រាស់ធនធានធម្មជាតិ<br>- សិទ្ធិចាស់ស្រុកចាស់ទុំ | | |

| | | | |
|---|---|---|---|
| ១ | - អាជ្ញាធរប្រព៉ៃណីខ្សោយ-មិនសូវមានលារគិតគូរ<br>- ការកំណត់ដីលំនៅដ្ឋាន<br>- ការរារាំងមិនឱ្យកំណត់ដីលំនៅដ្ឋាន ព្រៃកស្វាយ -ថ្មដូនពៅ<br>- ការរារាំងរបស់អាជ្ញាធរមូលដ្ឋានមិនឱ្យកាប់ដី ចំការវិលជុំ<br>- មិនមានការចែកដីប្រើប្រាស់និងដីអភិរក្ស<br>- ការរារាំងមិនឱ្យរកអនុផលព្រៃឈើ ដូចជា គ្រាប់សំរ៉ង ជាដើម<br>- គ្មានសាលារៀនសម្រាប់ក្មេងជំនាន់ក្រោយ<br>- ការបង្ខំឱ្យសហគមន៏ចេញពីតំបន់អភិរក្ស ( ថ្មបាំង)<br>- ណែនាំ ចចារ ប្តូរដី ( ប៉ូលីស មេព្រៃ - IC)<br>- អាជ្ញាធរបាញ់គំរាម ចាប់ រារាំងមិនឱ្យគ្រួរសា ២ ធ្វើស្រែចំការ របស់គាត់<br>- មេឃុំយកដីពលរដ្ឋ ១០ ហិចតា ( ឃុំតាតី-ថ្មបាំង)<br>- អ្នកចំណូលថ្មីចូលដណ្តើមដីជនជាតិ ( រំដេង អន្លង់រុន)<br>- មនុស្សជំនាន់ថ្មីមិនស្តាប់តំបូន្មានចាស់ទុំ<br>- សហគមន៏ជនជាតិដើមភាគតិចមិនមានឥទ្ធិពល ដើម្បីថែរក្សា ការពារព្រៃឈើ<br>- អ្នកមានអំណាចវាទយកដីអ្នកភូមិ<br>- បាត់បង់ភាសាដើម | - បង្កើតសហគមន៏ជនជាតិដើមភាគតិចឱ្យបាន គ្រប់ទីកន្លែង និងឱ្យពេញផ្លូវច្បាប់<br>- ពង្រឹងសមត្ថភាពសហគមន៏លើវិស័យច្បាប់ សិទ្ធិ និងសង្គម<br>- ដោះស្រាយបញ្ហាដីធ្លីសម្រាប់សង់ផ្ទះសហគមន៏ ស្រែ-ចំការ-កំណត់ដីសហគមន៏<br>- បង្កើតមុខរបរចិញ្ចឹមគ្រួសារ-សហគមន៏<br>- ត្រូវការសាលារៀននៅតាមសហគមន៏នីមួយៗ<br>- ផ្តល់សេវាសុខភាព<br>- បង្កើតសហគមន៏ព្រៃឈើ<br>- ដីទឹកពុះជាមួយក្រុមហ៊ុនចិន | - ដោយសារអាជ្ញាធរប្រព៉ៃណីខ្សោយ ត្រូវការជំនួយស្មារតីពីអង្គការ NGOs<br>- ពង្រឹងការចូលរួមផ្សព្វផ្សាយអំពីសិទ្ធិ និងច្បាប់ ការរស់នៅ វប្បធម៌ ការអប់រំ និងការតាំង ទីលំនៅដ្ឋាន និងសំណូមពរឱ្យ ILO សម្រប សម្រួលផ្តល់ថវិកាអនុវត្តអនុសាសន៏ ទាំងនេះ<br>- រួបរួមគ្នាក្នុងសហគមន៏<br>- លើកយោបល់ទៅអាជ្ញាធរប្រព៉ៃណី និង NGOs<br>- ជួយដោះស្រាយបញ្ហារបស់សហគមន៏<br>- សុំថវិកាសំរាប់សេវាកម្មដោះស្រាយបញ្ហា<br>- ដោះស្រាយរកទីផ្សារសំរាប់ដំណាំកសិកម្ម<br>- ធ្វើផ្លូវ<br>- ផ្តល់ការអប់រំមុខជំនាញ វិជ្ជាជីវៈផ្សេងៗ និងបច្ចេកទេសដាំដំណាំ<br>- សហគមន៏មានដីបំរុងទុក ឈើសម្រាប់កែឆ្លែសាងសង់<br>- សុំឱ្យអង្គការជួយថវិកាសាងសង់សាលា<br>- សង់មណ្ឌលសុខភាពចលត័តាមភូមិ |

| | | | |
|---|---|---|---|
| | - ខ្វះមុខរបរចិញ្ចឹមជីវិតតាមកាលៈទេសៈធម្មជាតិប្រែ ប្រួល | | - ផ្សព្វផ្សាយសុខភាព អនាម័យដល់សហគមន៍<br>- សំណូមពរឱ្យ ណាអឿស ដែលធ្វើការលើជនជាតិដើមភាគតិចចូលរួមបង្កើតគោលការណ៍សហគមន៍ព្រៃឈើ និងសម្របសម្រួលដំណើការ<br>- ពង្រឹងការចូលរួមផ្សព្វផ្សាយច្បាប់រៀបចំសហគមន៍<br>- សុំឱ្យរដ្ឋាភិបាលជួយសម្រួលជាមួយក្រុមហ៊ុនចិនកុំឱ្យបាត់ដីជនចាតិដើមតំបន់ទឹកពុះ<br>- សំណូមពរឱ្យមានការគាំទ្រពីអង្គការ ពិសេស ILO |

បន្ទាប់មកសម័យប្រជុំពេញអង្គបានពិភាក្សាគ្នាលើការបង្ហាញរបស់ក្រុមទាំងអស់ ក្នុងបំណងអោយទទួលបាននូវចង្កោម អាទិភាពមួយដែលឆ្លុះបញ្ចាំង និងរួមផ្សំនិងអាទិភាពដែលក្រុមនិមួយៗរកឃើញ ។ ការពិភាក្សាបានសន្និដ្ឋានថាខាងក្រោមនេះ គឺជាបញ្ហាសំខាន់បំផុតដែលជនជាតិដើមភាគតិច ចង់បានការជួយដោះស្រាយ :

1- ដីធ្លី
2- ព្រៃឈើ
3- ច្បាប់ប្រពៃណី វប្បធម៌ និងទំនៀមទំលាប់
4- សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច
5- សុខភាព
6- ការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ

បន្ទាប់មកពួកគេបានពិភាក្សានិងបានសំរេចថា "សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច" ជាភាគមួយនៃប្រធានបទទាំងអស់ ដែលត្រូវបានរកឃើញ និងគួរដោះស្រាយជាបញ្ហាពាក់ព័ន្ធមួយ ។

សិក្ខាសាលាថ្ងៃទីមួយត្រូវបានបិទដោយ Ms Birgitte Feiring, ជាប្រធានទីប្រឹក្សាបច្ចេកទេស (CTA) ប្រចាំគំរោង ILO ដើម្បីជំរុញគោលនយោបាយ ILO ចំពោះជនជាតិដើមភាគតិច និងប្រជាជនកុលសម្ព័ន្ធ (PRO 169) និងលោកសេក សោភ័ណ។ មុនពេលបិទសិក្ខាសាលាថ្ងៃទីមួយ មានការជូនដំណឹងដល់អ្នកចូលរួមអំពីដំណើរការនិង ទស្សនៈរួមនៃសិក្ខាសាលាថ្ងៃទីពីរ ។

## ថ្ងៃទីពីរ : ការសម្ភោធគំរោងនិងការចែករំលែកបទពិសោធន៍របស់អ្នកពាក់ព័ន្ធជាពហុភាគី

### សេចក្តីផ្តើម

សិក្ខាសាលាថ្ងៃទីពីរ (6 ឧសភា) បានធ្វើឡើងសំរាប់ការពិភាក្សារបស់អ្នកពាក់ព័ន្ធ ជាពហុភាគី ដោយមានការចូលរួមពីស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ NGOs អង្គការអន្តរជាតិ និងម្ចាស់ជំនួយទ្វេភាគី និងពហុភាគី ។ មានការបង្ហាញអំពីអាទិភាព ដែលបានរកឃើញក្នុងថ្ងៃទីមួយ ការបង្ហាញអំពីគំរោង និងទិដ្ឋភាពផ្សេងៗនៃគោលនយោបាយពាក់ព័ន្ធ និងជនជាតិដើមភាគតិចនៅកម្ពុជា ដើម្បីជូនដំណឹងដល់សម័យប្រជុំពេញអង្គ និងការពិភាក្សាតាមក្រុម ។ បន្ទាប់ពីការបង្ហាញមានការពិភាក្សាតាមក្រុម អំពីប្រធាន បទបញ្ហាជាក់លាក់ដែលបានរកឃើញថា ជាអាទិភាពដោយ ITPs នៅថ្ងៃទីមួយ។ អ្នកតំណាងក្រុមនិមួយៗ បានបង្ហាញអនុសាសន៍របស់ខ្លួនដល់សម័យប្រជុំពេញអង្គ។

### សុន្ទរកថាស្វាគមន៍ដោយ Ms Ginette Forgues, ជាអ្នកឯកទេសជាន់ខ្ពស់ផ្នែកយុទ្ធសាស្ត្រក្នុងស្រុក សំរាប់ការងារសមរម្យ ILO-SRO បាងកក

Ms Forgues, ជាជនបង្គោលរបស់គំរោងនៅការិយាល័យអនុតំបន់ ILO ក្នុងទីក្រុងបាងកក (SRO) បានសំដែង នូវការស្វាគមន៍យ៉ាងកក់ក្តៅដល់អ្នកចូលរួមទាំងអស់ តាងនាមឱ្យនាយក ILO/SRO ។ នៅក្នុងសុន្ទរកថាបើករបស់គាត់ គាត់បានពន្យល់ថាគំរោងនេះជាផ្នែកមួយនៃកម្មវិធី ILO នៅកម្ពុជាដែលមាន 15 គំរោងនិងគំនិតផ្តួចផ្តើមច្រើនទៀតនៅក្នុងវិស័យខាងក្រោម :

- ពលកម្មកុមារ
- ការជួញដូរ
- HIV/ AIDS
- ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច
- សេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ភាពជាសហគ្រិនរបស់ស្ត្រី
- លក្ខខ័ណ្ឌការងារក្នុងរោងចក្រកាត់ដេរ
- ក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ផ្លូវលំជនបទ និងហេដ្ឋារចនាសម្ព័ន្ធ
- ជនពិការ
- គ្រោះថ្នាក់នៅពេលធ្វើការក្នុងសន្តិសុខសង្គម
- ការអប់រំកម្មករ

Ms Forgues បានគូសបញ្ជាក់ថា ថ្វីបើគំរោងនិងវិស័យទាំងនេះអាចមានទំរង់ផ្សេងគ្នា ប៉ុន្តែវាស្ថិតនៅក្នុងទិស ដៅតែមួយគឺថាការងារសមស្រប ។ សំរាប់ ILO ការងារសមស្របមានន័យថា :

1- ការទទួលបានការងារ ជាមួយនិយោជកម្នាក់ឬការងារដែលបង្កើតដោយនរណាម្នាក់ក៏ដោយ ។
2- ការងារដែលមានសិទ្ធិនិងលក្ខខ័ណ្ឌជាអប្បបរិមា ។
3- ការងារដែលផ្តល់ឱកាសដល់វិវឌ្ឍនភាពជាបុគ្គលនិងដែលអាចទ្រទ្រង់រក្សាគ្រួសារមួយបាន ។
4- ការងារដែលមានសុវត្ថិភាពនិងអាចទទួលបានសេវាសុខភាព ការអប់រំ និង កិច្ចការពារសង្គម ។
5- ការងារដែលអនុញ្ញាតឱ្យមានការពិភាក្សាក្នុងសង្គមរវាងកម្មករ និយោជកនិងរដ្ឋាភិបាល ដើម្បីឱ្យកម្មករ អាចសំដែងតំរូវការរបស់ខ្លួន និងអាចចូលរួមក្នុងសេចក្តីសំរេចចិត្តដែលប៉ះពាល់ដល់ការងារនិងការរស់នៅ របស់ខ្លួន ។

Ms Forgues បានបញ្ជាក់ថាគំរោងនេះជាផ្នែកនៃផែនការជាតិ សំរាប់ការងារសមស្របដែលបានព្រាងឡើងរួមគ្នាដោយ ILO រដ្ឋាភិបាលកម្ពុជា និង អង្គការនិយោជក និង កម្មករ ។ គោលបំណងមួយនៃផែនការនេះគឺដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនិងប្រជាជនដែលងាយរងគ្រោះ ។ ផែនការនេះស្របគ្នាជាមួយផែនការជាតិដើម្បីអភិវឌ្ឍសេដ្ឋកិច្ច-សង្គម យុទ្ធសាស្ត្រជាតិដើម្បីកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រចតុកោណ ។

ជាចុងបញ្ចប់ Ms Forgues បានថ្លែងថា គាត់ទន្ទឹងរង់ចាំដោយរីករាយដើម្បីសហការនិងធ្វើជាដៃគូជាមួយអង្គការ ជនជាតិដើមភាគតិច និងប្រជាជនកុលសម្ព័ន្ធ ជាមួយអាជ្ញាធរមូលដ្ឋាន ខេត្តនិងថ្នាក់ជាតិ ជាមួយ NGOs ដែលធ្វើ ការងារលើវិស័យនេះ ក៏ដូចជាអង្គការអន្តរជាតិនិងទីភ្នាក់ងារ UN ឯទៀត ហើយកិច្ចសហការនេះបានចាប់ផ្តើមរួច ហើយដោយការរៀបចំសិក្ខាសាលានេះ ។

## *សុន្ទរកថាបើកដោយឯកឧត្តមបណ្ឌិត ប៉ែន ដារ៉េត ជាសមាជិកក្រុមប្រឹក្សាធ្មេញច្បាប់*

បណ្ឌិតប៉ែន ដារ៉េត បាននិយាយថាគាត់រីករាយដែលមានឱកាសបើក សិក្ខាសាលានេះដែលមានបំណងអភិវឌ្ឍសិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជា ។ គាត់បានសង្កត់ធ្ងន់ថាការជជែកវែកញែក អំពីបញ្ហាជនជាតិដើមភាគតិច មានការរីកចំរើនគួរឱ្យកត់សំគាល់នៅកម្ពុជា ប្រសិនបើប្រៀបធៀបនិងប្រទេសឯទៀតក្នុងតំបន់ ។ គាត់បាននិយាយថា រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការងារដោយរលូន ដើម្បីជំរុញសិទ្ធិជនជាតិដើមភាគតិច ។ គាត់បានលើកឧទាហរណ៍ ពីការបង្កើតគណៈកម្មាធិការអន្តរក្រសួងដើម្បីអភិវឌ្ឍន៍ប្រជាជនតំបន់ភ្នំ (IMC) ពង្រាងគោលនយោបាយទូទៅ ដើម្បីអភិវឌ្ឍប្រជាជនតំបន់ភ្នំ ការអនុវត្តន៍របស់រដ្ឋាភិបាលលើអនុសាសន៍ដែលជាលទ្ធផលទទួលបានពីគំរោងស្រាវជ្រាវក្នុងឆ្នាំ1995 ដែលរូបគាត់ជានាយកគំរោងនោះ

ផ្នែកមួយនៅក្នុងច្បាប់ភូមិបាលអំពីសិទ្ធិកាន់កាប់ ដីធ្លីថ្នាក់ឃុំរបស់ជនជាតិ ដើមភាគតិចនិងការបង្កើតក្រុមការងារពិសេសថ្នាក់ជាតិ ដើម្បីអនុវត្តបទបញ្ញត្តិនៅក្នុងផ្នែកនេះនិងជាចុងក្រោយកត្តាដែលថា រដ្ឋាភិបាលកម្ពុជាបានស្នើសុំ ILO ឱ្យអនុវត្តសកម្មភាពសហប្រតិបត្តិការបច្ចេកទេស ដើម្បីអភិវឌ្ឍសិទ្ធិ ប្រជាជនទាំងនេះ ។

ឯកឧត្តមប៉ែន ដារ៉េត បានថ្លែងថាថ្វីបើមានកិច្ចប្រឹងប្រែងទាំងនេះ តែជនជាតិដើមភាគតិចនៅកម្ពុជាកំពុងតែប្រឈមមុខ និងការគំរាមកំហែងជាច្រើនដូចជា បញ្ហាដីធ្លី បរិស្ថាន ធនធានធម្មជាតិ ការអប់រំសុខភាពនិងសិទ្ធិមនុស្ស ។ ដូច្នេះគាត់រីករាយណាស់ដែល ILO ទទួលបញ្ហានេះ ជាពិសេសការផ្តល់ឱ្យការពិសោធន៍ដ៏យូរលង់របស់អង្គការ ក្នុងការដោះស្រាយបញ្ហាទាំងនេះ ដែលមានចែងក្នុងអនុសញ្ញាជនជាតិ ដើមភាគតិចនិងប្រជាជនកុលសម្ព័ន្ធរបស់ ILO ( អនុសញ្ញាលេខ 169 ) ។




ការពិគ្រោះយោបល់និងការចូលរួម គឺជាគោលការណ៍ស្នូលនៃអនុសញ្ញានេះ ដែលមានពាក់ព័ន្ធនិងកម្ពុជា ដោយសារផលប្រយោជន៍ជាក់លាក់របស់ជនជាតិដើមភាគតិច មិនត្រូវបានចែងសមស្របក្នុងច្បាប់និងក្នុងការធ្វើសេចក្តីសំរេចចិត្តគោលនយោបាយថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ។ ដោយគ្មានការពិគ្រោះយោបល់ និងការចូលរួមគ្រប់គ្រាន់ កម្មវិធីដោះស្រាយបញ្ហាជនជាតិដើមភាគតិច នឹងមិនមាននិរន្តរភាពទេ ដោយសារអវិជ្ជមានភាពនៃសេដ្ឋកិច្ចនិង ផលវិបាកសង្គម ។

បណ្ឌិតប៉ែន ដារ៉េត បាននិយាយថាគាត់មានជំនឿថាគំរោង ILO នឹងរួមចំណែកក្នុងការកាត់បន្ថយគម្លាតរវាងតំរូវការនៅថ្នាក់មូលដ្ឋាន និងការអភិវឌ្ឍន៍នៅថ្នាក់ជាតិ គោលនយោបាយថ្នាក់ជាតិ ហើយដាក់រចនាសម្ព័ន្ធឱ្យដំណើរការ ដែលអ្នកតំណាងជនជាតិដើមភាគតិចអាចរួមចំណែកអភិវឌ្ឍគោលនយោបាយ និងកម្មវិធីដែលសមស្របនិង ឆ្លើយតបចំពោះអាទិភាពនិងតំរូវការពិតប្រាកដរបស់ខ្លួន។

បណ្ឌិត ប៉ែន ដារ៉េត បានគូសបញ្ជាក់ពីសារៈសំខាន់នៃវិធានការដូចខាងក្រោម ដើម្បីសំរេចគោលបំណងទាំងនេះ :

- ការកសាងសមត្ថភាពអង្គការ ជនជាតិដើមភាគតិច ដែលមានស្រាប់និងជំរុញការបង្កើតអង្គការបន្ថែមទៀត សហព័ន្ធមួយរបស់ជនជាតិដើមភាគតិច នឹងអនុញ្ញាត្តិអោយក្រុមផ្សេងៗនិយាយជាសម្លេងតែមួយ និងមានឥទ្ធិពលលើការអភិវឌ្ឍន៍ និងការអនុវត្តន៍ច្បាប់ និងគោលនយោបាយពាក់ព័ន្ធ។
- គួរបង្កើតក្រុមប្រឹក្សាផ្តល់មតិមួយសំរាប់ជនជាតិដើមភាគតិច ដែលក្រុមផ្សេងៗអាចស្នើសុំគោលនយោបាយសំរាប់ក្រុមគេផ្ទាល់ ។ គួរមានការគាំទ្រនិងលើកទឹកចិត្តដល់ជនជាតិដើមភាគតិចឱ្យចូល រួមក្នុងគោលនយោបាយ និងការធ្វើសេចក្តីសំរេចចិត្ត ។
- ការជំរុញឱ្យមានការសិក្សានិងស្រាវជ្រាវបញ្ហាជនជាតិដើមភាគតិចដោយមានការចូលរួមយ៉ាងសកម្មពីក្រុមទាំងនេះ មានសារៈសំខាន់ជាទីបំផុត ដើម្បីសំរេចការផ្តល់អំណាចដល់ជនជាតិដើមភាគតិចនិងជំរុញឱ្យមានការយល់គ្នាទៅវិញទៅមកនិងជំរុញឱ្យសង្គមពហុវប្បធម៌មានការរីកចំរើន ។

ជាចុងបញ្ចប់ បណ្ឌិតប៉ែន ដារ៉េត បាននិយាយថាសិក្ខាសាលានេះ ជាជំហានយ៉ាងសំខាន់មួយក្នុងទិសដៅត្រឹមត្រូវ ហើយការវិវត្តន៍ច្រើនទៀតនឹងបានធ្វើឡើងក្នុងដំណើរការអនុវត្តគំរោង ILO។ ដោយបានឃើញចំនួនអ្នកតំណាងជនជាតិដើមភាគតិចដ៏ច្រើន គាត់បាននិយាយថាគាត់មានជំនឿថាសិក្ខាសាលា នឹងទទួលយកគោលការណ៍ពិគ្រោះយោបល់ និងការចូលរួម ឯអនុសាសន៍ដែលជាលទ្ធផល នឹងឆ្លុះបញ្ចាំងនូវសិទ្ធិ ផលប្រយោជន៍និងអាទិភាពរបស់ជន ជាតិដើមភាគតិចដោយខ្លួនឯង ។

## *អង្គការ ILO និងជនជាតិដើមភាគតិចនៅកម្ពុជា ដោយMs Birgitte Feiring, ជាប្រធានទីប្រឹក្សាបច្ចេកទេសរបស់ ILO, PRO 169*

Ms Feiring បានថ្លែងអំណរគុណអ្នកចូលរួមទាំងអស់ដែលបានមកចូលរួមក្នុងសិក្ខាសាលា ។ គាត់បានសង្កត់ធ្ងន់ពីសារៈសំខាន់ដែល ILO ស្វែងរកការបូកផ្សំគ្នារវាងកម្មវិធីផ្សេងៗ និងដើម្បីធានាការបន្ថែមឱ្យគ្នា ។ គាត់បានបញ្ជាក់ថា ILOមានប្រវត្តិធ្វើការងារជាមួយជនជាតិដើមភាគតិចជាយូរលង់ណាស់មកហើយ ILO ទទួលខុសត្រូវ ក្នុងការជួយផ្តល់ឧបករណ៍អន្តរជាតិលើវិស័យច្បាប់ តែប៉ុណ្ណោះដើម្បីការពារសិទ្ធិប្រជាជនទាំងនេះ។ អនុសញ្ញា ILO លេខ 169។ អង្គការ ILO បានអនុម័តអនុសញ្ញានេះ ដើម្បីប្រឆាំងការរើសអើងលើជនជាតិដើមភាគតិច ដែលមានបង្ហាញក្នុងវិស័យដែលជាកង្វល់សំខាន់របស់ ILO ដូចជាពលកម្មដោយបង្ខំ ពលកម្មកុមារ ការទទួលប្រាក់កំរៃ ស្មើគ្នាចំពោះការងារដូចគ្នា វិសមភាពថ្លៃឈ្នួល ការរើសអើង និងការទទួលបានការអប់រំនិងដីធ្លី ។ អនុសញ្ញាលេខ 169 ជាឧបករណ៍ងាយយល់ដែលគ្របដណ្តប់ដល់សិទ្ធិជាច្រើន ក្នុងចំណោមនោះមានសិទ្ធិទទួលការអភិវឌ្ឍន៍ ទទួល ដីធ្លីនិងធនធាននិងសិទ្ធិទទួលបានការអប់រំ ។ មានវិធីទ្វេដងដែលតំរូវឱ្យជនជាតិដើមភាគតិចទទួលផលប្រយោជន៍ពីសិទ្ធិស្មើគ្នា និងឱកាស នៅពេលដែលការអភិវឌ្ឍន៍យ៉ាងពេញលេញនូវសក្តានុពលភាពផ្ទាល់ខ្លួនរបស់គេ ដោយអនុលោមតាមអាទិ ភាព និងបំណងរបស់គេផ្ទាល់ ។ បទបញ្ញត្តិយ៉ាងសំខាន់បំផុតនៃអនុសញ្ញាគឺការពិគ្រោះយោបល់និងការចូលរួមដែលត្រូវយល់ឱ្យបានច្បាស់ថា ជាដំណើរការជាបន្ត ហើយនិងមិនមានអ្វីដែលត្រូវបានសំរេចដែលឈរលើមូលដ្ឋាន សាកល្បង (adhoc) មួយឬជាព្រឹត្តិការណ៍មួយនោះទេ។



មានប្រទេសចំនួន 17 បានផ្តល់សច្ចាប័នលើអនុសញ្ញាលេខ 169 ដែលត្រូវបានប្រើជាឯកសារយោងទូទាំងសកលលោកសំរាប់ការពិភាក្សានិងកំណត់សិទ្ធិជនជាតិដើមភាគតិច ។ អនុសញ្ញានេះ មានមុខងារជាមគ្គុទ្ទេសក៏ណែនាំពី របៀបជំរុញការចូលរួមក្នុងគោលនយោបាយ ការទទួលស្គាល់វប្បធម៌ ភាសា សិទ្ធិទទួលបានដីធ្លី និងធនធាន និងការបង្កើតយន្តការនិងស្ថាប័នសមស្រប សំរាប់ការពិគ្រោះយោបល់និងការចូលរួម ។ អនុសញ្ញាមានផលប៉ះពាល់ជាសំខាន់លើសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលឆ្លុះបញ្ចាំងក្នុងកត្តាគោលនយោបាយម្ចាស់ជំនួយពាក់ព័ន្ធរបស់ EU នករវ៉េ និងដាណឺម៉ាក ក្នុងចំណោមឯទៀតដែលឈរលើមូលដ្ឋាននៃបទបញ្ញត្តិរបស់ខ្លួន ។ អង្គការ ILO មានតួនាទីពីរ ដែលមិនត្រឹមតែដោះស្រាយតំរូវការសំរាប់ក្របខ័ណ្ឌគោលនយោបាយសមស្របប៉ុណ្ណោះទេ ប៉ុន្តែដោះស្រាយតំរូវការសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយមាននិរន្តរភាពក្នុងសហគមន៍ជនជាតិដើមភាគតិចផងដែរ ដោយស្របតាម ទស្សនះអភិវឌ្ឍតាមជំនឿផ្ទាល់ខ្លួនរបស់ប្រជាជនទាំងនេះ ។ តួនាទីទាំងពីរនេះមានការពាក់ព័ន្ធយ៉ាងខ្លាំងនៅក្នុង កម្ពុជា ។

Ms Feiring បានថ្លែងថានៅពេលដែល " គោលនយោបាយទូទៅដើម្បីអភិវឌ្ឍប្រជាជនតំបន់ភ្នំ " ត្រូវបានអនុម័ត ហើយការប្រឈមមុខជាច្រើនដែលនៅសល់នោះគឺការអនុវត្តន៍បទបញ្ញត្តិ ។ ការបង្កើតគោលនយោបាយសមស្រប និងក្របខ័ណ្ឌការងារស្ថាប័ន និងការកសាងសមត្ថភាពដើម្បីប្រាកដក្នុងចិត្តថាចំណុចទាំងនេះត្រូវបានដាក់ឱ្យដំណើរការ និង ប្រើប្រាស់ ដែលជាគន្លិះក្នុងការសំរេចការអនុវត្តន៍ដ៏មានប្រសិទ្ធិភាព ។ ការកសាងសមត្ថភាពគួរមានការ ចូលរួមពិភាក្សាយ៉ាងពិតប្រាកដរវាងភាគីពាក់ព័ន្ធទាំងអស់រួមទាំងរដ្ឋាភិបាលនៅក៏រិតផ្សេងៗ ដៃគូជនជាតិដើមភាគតិច និងអង្គការសង្គមស៊ីវិល។ ILO មានបទពិសោធន៍ជាយូរយារណាស់មកហើយ ទាំងក្នុងការកសាងសមត្ថភាពនិងគោលនយោបាយ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចដែលពាក់ព័ន្ធនិងជនជាតិដើមភាគតិច។ Ms Feiring បានថ្លែងថា ILO កំពុងទន្ទឹងរង់ចាំធ្វើការងារជាមួយអ្នកពាក់ព័ន្ធទាំងអស់ ដោយសង្ឃឹមថានឹងរួមចំណែកជាមួយបទ ពិសោធន៍នានារបស់អង្គការសំរាប់ផលប្រយោជន៍មិនត្រឹមតែជនជាតិដើមភាគតិចប៉ុណ្ណោះទេ ក៏ប៉ុន្តែសំរាប់ប្រជាជនទាំងអស់នៅកម្ពុជាផងដែរ ។

## *ទស្សនះរួមអំពីគំរោងជនជាតិដើមភាគតិចនៅកម្ពុជាដោយ លោកសេក សោភ័ណ ជាអ្នកសំរបសំរួលគំរោងថ្នាក់ជាតិ*

បន្ទាប់ពីធ្វើបដិសណ្ឋារកិច្ចចំពោះអ្នកចូលរួមលោកសេក សោភ័ណ បានថ្លែងថាអង្គការជាតិ និងអន្តរជាតិជាច្រើន ក៏ដូចជាស្ថាប័នរដ្ឋាភិបាលនៅកម្ពុជាបានអនុវត្តសកម្មភាពជាច្រើនដែលពាក់ព័ន្ធ ដើម្បីជនជាតិដើមភាគតិច និងប្រជាជនកុលសម្ព័ន្ធ ដោយអនុលោមតាមអាណត្តិនិងតួនាទីរបស់ខ្លួន។ សកម្មភាព

ទាំងនេះពាក់ព័ន្ធនិងសិទ្ធិជាច្រើនរបស់ ជនជាតិដើមភាគតិច ដូចជាសិទ្ធិទទួលបានដីធ្លី ការអប់រំ សុខភាព និងភាពថ្លៃថ្នូរ ។ ភាគច្រើនបំផុតនៃសកម្មភាព ទាំងនេះបានផ្តោតលើទិដ្ឋភាពផ្សេងៗនៃសិទ្ធិទទួលបានដីធ្លី។ គាត់បានគូសបញ្ជាក់ថា អាណត្តិរបស់ ILO ដើម្បីជំរុញសិទ្ធិរបស់ជនជាតិដើមភាគតិច គឺឈរលើមូលដ្ឋាន អនុសញ្ញា ILO លេខ 169។ អនុលោមតាមអនុសញ្ញានេះ គំរោង ILO មានគោលបំណងបន្ថែមតំលៃ លើសកម្មភាពពាក់ព័ន្ធរបស់អង្គការសង្គមស៊ីវិល និងស្ថាប័នរដ្ឋាភិបាលផ្សេងៗ។ គំរោងមានរយៈពេល ចាប់ផ្តើមដំបូងមួយឆ្នាំ។

លោកសេកសោភ័ណ បានជូនពត៌មានថាគំរោងផ្តោតជាសំខាន់លើការគាំទ្រការបង្កើតគោលនយោបាយ ដែលពាក់ព័ន្ធជនជាតិដើមភាគតិច និងការកសាងសមត្ថភាពសំរាប់ស្ថាប័នរដ្ឋាភិបាល NGOs និងអង្គការ ជនជាតិដើមភាគតិច ។ គំរោងនឹងត្រូវបានអនុវត្តក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល សង្គមស៊ីវិល និង អង្គការជនជាតិដើមភាគតិច ជាពិសេស MRD NGOs ដែលធ្វើការងារលើបញ្ហាជនជាតិដើមភាគតិច និងសមាគមប្រជាជនតំបន់ភ្នំ ។

លោកសេក សោភ័ណ បានបញ្ជាក់ថាគំរោងនឹងសំរបសំរួលយ៉ាងជិតស្និទ្ធជាមួយអង្គការអន្តរជាតិ ។ គាត់បានបង្ហាញថា រយៈពេលមួយឆ្នាំដំបូងនៃគំរោងមិនគ្រប់គ្រាន់ ដើម្បីសំរេចឱ្យបានលទ្ធផលដូចរំពឹងទុក ទេ ចំពោះការបណ្តុះបណ្តាល និងការកសាងសមត្ថភាពហើយថាគំរោងនឹងមានឱកាសពង្រីកថែមទៀត ។ ជាចុងបញ្ចប់គាត់បានថ្លែងថា គំរោងមិនទាន់បានបង្កើតផែនការសកម្មភាពជាលំអិតមួយនៅឡើយទេ ហើយ គាត់សង្ឃឹមថា លទ្ធផលពីសិក្ខាសាលានេះ ជាជំហានដ៏សំខាន់មួយក្នុងការបង្កើតផែនការការងារ ដែលឆ្លុះ បញ្ចាំង គោលការណ៍នៃការពិគ្រោះយោបល់ និងការចូលរួម ។

## *ការបង្ហាញអនុសាសន៍ពីជនជាតិដើមភាគតិច*

### លោកខាំ សាញ់

លោកខាំ សាញ់បានបង្ហាញបញ្ហាសំខាន់ៗ ការពិភាក្សានិងអនុសាសន៍ពីថ្ងៃទីមួយ

| បញ្ហា អាទិភាព | អនុសាសន៍ |
|---|---|
| **១. ដីធ្លី**<br>- ការហូរចូលពីអ្នកក្រៅ<br>- ការទិញ លក់ ខុសច្បាប់<br>- ការធ្វើសម្បទានដី | - សុំឱ្យកំណត់ព្រំប្រទល់ដីសហគមន៍ឱ្យច្បាស់ លាស់<br>- ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចឱ្យបាន ឆាប់<br>- សម្បទានដី ត្រូវសិក្សាពីការប៉ះពាល់ដល់ការរស់ នៅរបស់ជនជាតិដើមភាគតិច |
| **២. ការចូលរួមគ្រប់គ្រងធនធានធម្មជាតិ**<br>- បំផ្លាញព្រៃឈើ សត្វព្រៃ និងមច្ឆជាតិ<br>- គ្រោះធម្មជាតិ រាំងស្ងួត<br>- ការធ្វើសម្បទានរ៉ែ<br>- ទំនប់វារីអគ្គិសនី | - ផ្សព្វផ្សាយអំពីច្បាប់ព្រៃឈើនិងបរបាញ់ ការនេសាទតាមលក្ខណៈប្រពៃណី<br>- ទប់ស្កាត់ការបំផ្លាញព្រៃឈើ និងផ្តល់បច្ចេកទេសដាំដំណាំរួមផ្សំ<br>- សិក្សាពីដីទំនេរ ក្រៅពីដីរបស់សហគមន៍<br>- ម្ចាស់ជំនួយសិក្សាពីផលប៉ះពាល់និងបញ្ឈប់ការ ធ្វើទំនប់វារីអគ្គិសនី |
| **៣. វប្បធម៌ ប្រពៃណី**<br>- តួនាទីអាជ្ញាធរ<br>- ការហូរចូលសាសនាដ៏ទៃ<br>- ការបាត់បង់ភាសា<br>- សីលធម៌ | - គោរពតួនាទី និងប្រគល់សិទ្ធិឱ្យអាជ្ញាធរ ប្រពៃ ណី<br>- សុំឱ្យអង្គការបង្កើតឱ្យមានការអនុវត្តន៍ ចូរុះភា សា<br>- ដំណោះស្រាយតាមប្រពៃណី |
| **៤. ការអប់រំ**<br>- បង្រៀនភាសាជនជាតិ<br>- ផ្តល់សាលា និងគ្រូ<br>- ផ្សព្វផ្សាយច្បាប់ពាក់ពន្ធ័<br>- បញ្ចូលវប្បធិមជនជាតិក្នុងកម្មវិធីសិក្សា | - សុំឱ្យមានការបង្រៀនភាសាជនជាតិ និងភាសា ខ្មែរ<br>- ផ្តល់សាលា និងបណ្តុះបណ្តាលគ្រូ នៅតាមសហ គមន៍<br>- សុំឱ្យមានធនធានផ្សព្វផ្សាយច្បាប់ពាក់ពន្ធ័<br>- លើកស្ទួយវប្បធម៌ជនជាតិក្នុងកម្មវិធីសិក្សា ដោយមានការគាំទ្រពីអង្គការពាក់ពន្ធ័ និងពី រដ្ឋាភិបាល |

| | |
|---|---|
| **៥. សិទ្ធិ**<br>- គោលនយោបាយអភិវឌ្ឍសិទ្ធិជនជាតិដើម ភាគតិច<br>- រៀបចំលក្ខន្តិកៈសហគមន៍<br>- ចូលរួមធ្វើសេចក្ដីសម្រេចចិត្ត<br>- ការចូលរួមពិគ្រោះយោបល់<br>- គោរពច្បាប់ប្រពៃណី<br>- គោរពជំនឿ សាសនា | - រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលទំនាក់ ទំនងល្អ<br>- អង្គការពាក់ពន្ធ័រៀបចំលក្ខន្តិកៈ ច្បាប់ដល់សហគមន៍<br>- អង្គការជួយឱ្យសហគមន៍ចូលរួមក្នុងការ សម្រេចចិត្ត<br>- សុំឱ្យជួយឱ្យសហគមន៍ចូលរួមពិគ្រោះយោបល់<br>-ប្រគល់សិទ្ធិឱ្យសហគមន៍ គោរពច្បាប់ប្រពៃណី និងអាជ្ញាធរ ប្រពៃណី<br>- ផ្ដល់សិទ្ធិឱ្យសហគមន៍គោរពជំនឿសាសនា |
| **៦. សុខភាព**<br>- គ្មានមណ្ឌលសុខភាព ថ្នាំពេទ<br>- ការប្រើប្រាស់ថ្នាំពុលផ្សេងៗដោយមិនដឹង ច្បាស់ពី បច្ចេកទេស<br>- ពេលឈឺអស់លុយច្រើន | - សុំឱ្យអង្គការជូររដ្ឋាភិបាលសង់បន្ថែម នូវមណ្ឌលសុខភាព នៅជិតភូមិនិងផ្ដល់ថ្នាំពេទគ្រប់គ្រាន់<br>- បញ្ឈប់ការប្រើប្រាស់ថ្នាំពុលព្រោះមិនដឹងច្បាស់ពី បច្ចេក ទេស<br>- ផ្ដល់សេវាថ្នាំ ថោកល្មម |
| **៧. .ការអនុវត្តច្បាប់**<br>- ខ្វះការអនុវត្តច្បាប់រដ្ឋធម្មនុញ្ញ<br>- ច្បាប់ភូមិបាលឆ្នាំ ២០០១ និងអនុក្រិត្យ ពាក់ពន្ធ័ និងសហគមន៍ | - សុំឱ្យមានធនធានផ្សព្វផ្សាយ អនុវត្តច្បាប់រដ្ឋធម្មនុញ្ញ ដល់សហគមន៍<br>- រដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលផ្ដល់ធនធានចេះដឹង ខាងច្បាប់ភូមិបាល ២០០១និងអនុក្រិត្យពាក់ពន្ធ័នឹងសហគមន៍ |

## *នាយកដ្ឋានអភិវឌ្ឍជនជាតិដើមភាគតិច (DEMD) ដោយបណ្ឌិត សុត សឿង ជាអនុប្រធាននាយកដ្ឋាន DEMD*

នៅក្នុងការបង្ហាញរបស់គាត់ បណ្ឌិត សុត សឿង បានបំភ្លឺអំពីការរំលាយ IMC ការបង្កើត DEMD តួនាទីការទទួលខុសត្រូវគោលបំណងនិងសមិទ្ធិផល ។ ក្នុងឆ្នាំ 1999 ក្រុមប្រឹក្សារដ្ឋមន្ត្រីបានសំរេចចិត្តបង្កើត DEMD ហើយឱ្យនាយកដ្ឋាននេះ ទទួលខុសត្រូវលើកិច្ចការអភិវឌ្ឍន៍ទាំងអស់ ដែលពាក់ព័ន្ធជនជាតិដើម ភាគតិចនៅក្នុងតំបន់ភ្នំ ។ ដោយអនុលោមតាមអនុក្រិត្យលេខ 51 ចុះថ្ងៃទី 21 មិថុនា ឆ្នាំ 2001 នាយកដ្ឋាន DEMD មានអាណត្តិ និង ភារៈកិច្ចអភិវឌ្ឍជនជាតិដើមភាគតិចទាំងអស់នៅកម្ពុជា ។

បណ្ឌិត សុត សឿង បានគូសបញ្ជាក់តួនាទីនិងការទទួលខុសត្រូវរបស់ DEMD ដូចខាងក្រោម :

- រៀបចំផែនការអភិវឌ្ឍរយៈពេលខ្លី មធ្យម និង រយៈពេលវែងសំរាប់សហគមន៍ជនជាតិដើមភាគតិច
- សិក្សានិងស្រាវជ្រាវរកជនជាតិដើមភាគតិចដែលរស់នៅក្នុងតំបន់ភ្នំ រកប្រពៃណី វប្បធម៌ និង ទំនៀម ទំលាប់របស់ពួកគេឱ្យច្បាស់លាស់
- រៀបចំ អនុវត្តគំរោង និងកម្មវិធីសំរាប់ការអភិវឌ្ឍន៍ ITP នៅក្នុងតំបន់ភ្នំ
- សំរបសំរួលសកម្មភាពអភិវឌ្ឍពាក់ព័ន្ធនិងជនជាតិដើមភាគតិចនៅក្នុងតំបន់ភ្នំនៅកម្ពុជា
- ត្រួតពិនិត្យតាមដាន វាយតំលៃនិងរាយការណ៍សកម្មភាពទាំងអស់ដែលបានអនុវត្តក្នុងក្របខ័ណ្ឌនៃកម្មវិធី និងគំរោងសំរាប់ការអភិវឌ្ឍន៍ជនជាតិដើមភាគតិច
- បង្កើតលក្ខណៈវិនិច្ឆ័យសំរាប់ការបង្កើតសហគមន៍ជនជាតិដើមភាគតិច
- បង្កើត និងគ្រប់គ្រងមណ្ឌលពត៌មានមួយអំពីការងារអភិវឌ្ឍន៍តំបន់ភ្នំដោយសហប្រតិបត្តិការជាមួយ ស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិ NGOs និងប្រទេសជិតខាង
- រៀបចំនិងកែលំអរគោលនយោបាយ សំរាប់ការអភិវឌ្ឍន៍តំបន់ភ្នំដើម្បីដាក់ជូនរាជរដ្ឋាភិបាលកម្ពុជាសំរេច
- ផ្តល់ការបណ្តុះបណ្តាលដល់សេវាស៊ីវិលនៅគ្រប់កំរិតនៃការអភិវឌ្ឍន៍ជនជាតិដើមភាគតិច
- ស្វែងរកជំនួយពីម្ចាស់ជំនួយ អង្គការអន្តរជាតិ និង NGOs ។

បន្ទាប់ពីពន្យល់អំពីរចនាសម្ព័ន្ធរបស់នាយកដ្ឋានរួចហើយ បណ្ឌិត សុត សឿង បានគូសបញ្ជាក់អំពីសមិទ្ធិផលខ្លះ ដែលនាយកដ្ឋានសំរេចបានក្នុងនោះមានការស្រាវជ្រាវជនជាតិដើមភាគតិចនៅខេត្តមណ្ឌលគីរី ការចូលរួមក្នុងការ ពិគ្រោះយោបល់ថ្នាក់ជាតិនៅខេត្តកំពង់ស្ពឺ កំពង់ធំ ក្រចេះ ស្ទឹងត្រែង និង មណ្ឌលគីរី ។ ការចូលរួមក្នុងវេទិកាថ្នាក់ តំបន់នៅទីក្រុងបាងកក ការចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេស នៅខេត្តក្រចេះ និងការបណ្តុះបណ្តាលរៀបចំដោយ Health Unlimited នៅខេត្តរតនៈគីរី ។ វេជ្ជបណ្ឌិត សុត សឿង បានជូនពត៌មានដល់សិក្ខាសាលាអំពី សកម្មភាព កំពុងបន្តរបស់ DEMD ដូចខាងក្រោម :

- រៀបចំវេទិកាពិគ្រោះយោបល់មួយ ដើម្បីពិភាក្សាពង្រាងគោលនយោបាយប្រជាជនតំបន់ភ្នំនៅខេត្តកំពង់ស្ពឺ ក្នុងខែ ឧសភា 2005 និងនៅភ្នំពេញក្នុងខែ កក្កដា 2005 ។
- រៀបចំវេទិកាពិគ្រោះយោបល់ថ្នាក់ជាតិមួយ ដើម្បីពិភាក្សាពង្រាងគោលនយោបាយ មុនពេលដែលដាក់ពង្រាងនេះជាថ្មីជូនក្រុមប្រឹក្សារដ្ឋមន្ត្រីក្នុងខែ កញ្ញា 2005 ។
- ស្រាវជ្រាវដើម្បីរកជនជាតិដើមភាគតិចនៅទូទាំងប្រទេស ។
- ស្រាវជ្រាវនិងវាយតំលៃតំរូវការអំពីការគ្រប់គ្រងការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ។

- រៀបចំការប្រជុំមួយជាមួយម្ចាស់ជំនួយ អង្គការជាតិនិងអន្តរជាតិនិងស្ថាប័នរដ្ឋាភិបាល ដើម្បីបង្កើតក្រុមការងារមួយអំពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ។ ការប្រជុំនេះនឹងធ្វើឡើងនៅក្នុងឆ្នាំ 2005 ។

## *ជនជាតិដើមភាគតិច និងការកាត់បន្ថយភាពក្រីក្រដោយ Kristina Chhim ជាអ្នកសំរបសំរួលការស្រាវជ្រាវ ជាន់ខ្ពស់ មណ្ឌលការសិក្សាដើម្បីវិវឌ្ឍនភាព (CAS)*

បណ្ឌិត Kristina Chhim បានបង្ហាញទិដ្ឋភាពជាច្រើន នៃគំរោងស្រាវជ្រាវអំពីភាពក្រីក្ររបស់ជនជាតិដើមភាគតិចដោយ CAS និងផ្តល់កំរៃដោយ ILO ។ ការបង្ហាញបានបញ្ជាក់អំពីគោលបំណងនៃការសិក្សាវិធីសាស្ត្រ ទស្សនះរួមរបស់សហគមន៍ដែលត្រូវបានសិក្សាលទ្ធផលដែលពាក់ព័ន្ធជនជាតិដើមភាគតិច ការផ្លាស់ប្តូរទស្សនះទាននិងលក្ខណះវិនិច្ឆ័យអំពីភាពក្រីក្រ និងការកាត់បន្ថយភាពក្រីក្រការចូលរួមរបស់ពួកគេក្នុងការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រ (NPRS) តួនាទីរបស់រដ្ឋាភិបាល និងគោលបំណងផ្ទាល់របស់ជនជាតិដើមភាគតិច កង្វល់ និងសក្តានុពលភាពសំរាប់អភិវឌ្ឍ ។

កញ្ញា Chhim បានបញ្ចប់ការបង្ហាញរបស់គាត់ដោយមានពង្រាងអនុសាសន៍អាទិភាព ដោយឈរលើមូលដ្ឋានលទ្ធ ផលរបស់គាត់ :

- សន្តិសុខដីធ្លី
  - វិធានការណ៍ជាបន្ទាន់ដើម្បីបញ្ឈប់ការកាន់កាប់ដីធ្លីខុសច្បាប់ឬការបង្ខំឱ្យលក់ដីធ្លី
  - ពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិច អំពីសម្បទានដែលបានរៀបផែនការ

- សន្តិសុខក្នុងការចិញ្ចឹមជីវិត
  - គាំទ្រការផ្សព្វផ្សាយកសិកម្មឱ្យបានគ្រប់គ្រាន់សំរាប់ពូជនិងវិធីសាស្ត្រថ្មីៗ
  - គាំទ្រខាងបសុព្យាបាល
  - គាំទ្រឱ្យទទួលបានទីផ្សារ

- ការអប់រំក្នុងប្រព័ន្ធសមរម្យ
  - ផ្តល់ការបង្រៀនពីរភាសា និងផ្តល់សំភារៈសំរាប់បង្រៀនជាក់លាក់អំពីវប្បធមិ
  - គាំទ្រសិស្សជនជាតិដើមភាគតិចឱ្យក្លាយជាគ្រូបង្រៀន

- អត្តសញ្ញាណជនជាតិដើមភាគតិច.វិធីនៃការរស់នៅ
  - គាំទ្រអង្គការជនជាតិដើមភាគតិចខ្លួនឯងឱ្យហួសពីកំរិតភូមិ

## *ការពិភាក្សាក្នុងសម័យប្រជុំពេញអង្គ*

បន្ទាប់ពីការបង្ហាញ អ្នកចូលរួមទាំងអស់បានពិភាក្សាយ៉ាងសកម្មអំពីទិដ្ឋភាពផ្សេងៗរបស់ខ្លួន ។ ចំណុចសំខាន់ៗ នៃ ការពិភាក្សាមានដូចខាងក្រោម :

- អ្នកតំណាងម្នាក់មកពី UNDP បានជូនពត៌មានថាបច្ចុប្បន្ននេះ UNDP កំពុងធ្វើ ការស្រាវជ្រាវអំពីការទទួលបានយុត្តិធម៌ដោយយកចិត្តទុកដាក់ជាពិសេសលើជនក្រីក្រ ស្ត្រីនិងជនជាតិដើមភាគតិច។ គាត់បាន សង្កត់ធ្ងន់ថាសហគមន៍ជនជាតិដើមភាគតិចមានប្រព័ន្ធធ្វើសេចក្តីសំរេចចិត្តនិងដំណោះស្រាយជម្លោះរបស់ពួកគេផ្ទាល់ ដែលគួរត្រូវបានរៀបចំជាផ្លូវការនិងយកចិត្តទុកដាក់ជួយ ។ មានបញ្ហាសំខាន់ៗចំពោះជនជាតិ ដើមភាគតិចពីការទទួលបានស្ថាប័នយុត្តិធម៌ជាផ្លូវការដូចជាកិច្ចសន្យាដែលបានព្រាងជាភាសាខ្មែរ និងមានកង្វះខាតការបកប្រែក្នុងនិតិវិធី ។ សារៈសំខាន់ នៃកតិការអន្តរជាតិអំពីសិទ្ធិចូលរួមនយោបាយនិងសិទ្ធិ ជនស៊ីវិល (មាត្រា 27 ពាក់ព័ន្ធនិងសិទ្ធិជនជាតិដើមភាគតិច ) និងច្បាប់ភូមិបាល ( ពាក់ព័ន្ធនិងសិទ្ធិជន ជាតិដើមភាគតិចនិងច្បាប់ទំនៀមទំលាប់ជនជាតិដើមភាគតិច ) សំរាប់គំរោង ILO និងគោលនយោបាយសំរាប់ជនជាតិដើមភាគតិចនៅកម្ពុជាត្រូវបានបង្ហាញឡើង ។



- អ្នកចូលរួមម្នាក់មកពីខេត្តស្ទឹងត្រែងបានគូសបញ្ជាក់ពីបញ្ហាដែលសហគមន៍ជាច្រើនកំពុងប្រឈមមុខ ដោយសារការរុករករ៉ែដែលប៉ះពាល់ដល់ដីធ្លី និងព្រៃឈើដែលប្រជាជនពឹងពាក់អាស្រ័យ

ហើយវាគំរាមកំហែងដល់ជំនឿនិងវប្បធម៌របស់ពួកគេផងដែរ ។ ក្រុមហ៊ុនមួយបានយកដីធ្លីដោយគ្មានការពិគ្រោះយោបល់ជាមួយអ្នកភូមិឬផ្តល់ពត៌មានដល់អ្នកភូមិ ដែលឥឡូវនេះអ្នកភូមិ កំពុងប្រឈមមុខនិងបញ្ហា យ៉ាងធ្ងន់ធ្ងរប្រសិនបើមិនចាត់វិធានការណ៍ជាបន្ទាន់ទេនោះ ។

- អ្នកចូលរួមម្នាក់មកពីខេត្តមណ្ឌលគិរីបានរាយការណ៍ថាក្រុមហ៊ុនមួយបានទទួលដីទំហំ 200000 អារ ដែលពីអតីតកាលដីនេះជាដីដែលជនជាតិដើមភាគតិចធ្លាប់ដាំដើមស្វាយចន្ទី ។ ដីនេះក៏សំរាប់ជនជាតិដើមភាគ តិចតាំងទីលំនៅនិងសំរាប់ធ្វើជាកន្លែងកប់សពផងដែរ ។
- អ្នកចូលរួមម្នាក់ទៀត បានជូនពត៌មានអំពីការចូលកាន់កាប់ដីធ្លីនិងការប្រើថ្នាំសម្លាប់សត្វល្អិតដែលប៉ះពាល់សុខភាពសហគមន៍ ។ អ្នកភូមិបានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរស្រុកនិងខេត្ត ប៉ុន្តែអាជ្ញាធរបានប្រាប់អ្នកភូមិឱ្យរង់ចាំការដោះស្រាយបញ្ហានោះ ពីថ្នាក់លើដែលគ្មានអ្វីកើតឡើងសោះ ក្រោយរយៈពេលជាច្រើនខែ រួចមក ។
- អ្នកចូលរួមម្នាក់មកពីខេត្តរតនៈគិរី បានទាញអារម្មណ៍សម័យប្រជុំពេញអង្គថា មានក្រុមហ៊ុនបីដែលកំពុងប្រតិបត្តិការក្នុងខេត្តរតនៈគិរី ។ ស្ថានភាពពាក់ព័ន្ធដីធ្លីកាន់តែមានភាពធ្ងន់ធ្ងរឡើងៗនៅក្នុងសហគមន៍និមួយៗ ។ អ្នកខ្លះបានលក់ដី ឯអ្នកខ្លះទៀតមិនបានលក់អភិបាលស្រុក ទទួលបានរថយន្តមួយគ្រឿង ហើយឥឡូវនេះអ្នកឯទៀតកំពុងមានការច្រណែន ។ អ្នកចូលរួមបានជំរុញឱ្យអ្នកពាក់ព័ន្ធទាំងអស់ប្រឹងប្រែងរក ដំណោះស្រាយ ។
- អ្នកចូលរួមម្នាក់ទៀត ( សមាជិកម្នាក់នៃក្រុមស្ទួយ ) មកពីខេត្តកំពង់ស្ពឺបាននិយាយថារដ្ឋាភិបាលបានផ្តល់សម្បទានដីទំហំ 900 អារ ដើម្បីសាងសង់ទីលានវាយកូនហ្គោល និងសណ្ឋាគារមួយ ។ ដីសម្បទាននោះ ប៉ះពាល់ទីតាំងនៃបុព្វបុរសនៃប្រជាជនរបស់គាត់ ។
- សមាជិកជាជនជាតិស្ទៀងម្នាក់មកពីខេត្តក្រចេះ បានជូនពត៌មានថា មានក្រុមហ៊ុនមួយបានមកទាមទារដី ទំហំ 100 អារ ហើយបន្ទាប់មកបានចាប់ផ្តើមពង្រីកនិងគំរាមកំហែងអ្នកភូមិ ។
- អ្នកចូលរួមម្នាក់មកពីខេត្តកំពង់ចាម បាននិយាយថាសហគមន៍របស់គាត់រីករាយនឹងចាប់ផ្តើមចុះបញ្ជីដីធ្លី ។ ក្រុមហ៊ុនមួយបានមកដល់ហើយចាប់ផ្តើមកាប់ដើមឈើចាស់ៗចោល ហើយឆ្ការព្រៃដើម្បីធ្វើជាកន្លែងចិញ្ចឹមសត្វ ដោយមានកិច្ចសហការពីអ្នកភូមិជាបុគ្គលខ្លះ ។ ពួកគេបានជួបមេឃុំដើម្បីប្តឹង ប៉ុន្តែមិនមានដំណោះស្រាយ ។ បន្ទាប់មកសហគមន៍ត្រូវបានទទួលការចោទប្រកាន់ពីក្រុមហ៊ុននិងអាជ្ញាធរដែលបានលើកទឹកចិត្តប្រជាជនឱ្យកាប់ដើមឈើ ។ អ្នកចូលរួមនោះនិយាយថាមានព្រៃឈើខ្លះនៅសេសសល់នៅឡើយ ប៉ុន្តែប្រសិនបើសហគមន៍មិនអាចចុះបញ្ជីដីធ្លីរបស់ខ្លួនជាបន្ទាន់ទេ ព្រៃឈើនៅក្នុងតំបន់នោះនឹងត្រូវវិសាបសូន្យអស់ ។

- អ្នកចូលរួមម្នាក់បានសួរថាហេតុអ្វី ILO បង្កើតគំរោងនេះសំរាប់តែរយៈពេលមួយឆ្នាំ និងអ្វីជាលទ្ធផលដែលរំពឹងទុក ហើយថាតើ ILO មានយុទ្ធសាស្ត្រដើម្បីអនុវត្តក្នុងគ្រប់ខេត្តនៅកម្ពុជាដែរឬទេ។
- អ្នកចូលរួមម្នាក់ទៀតបាននិយាយថា គាត់អរគុណគំរោងអភិវឌ្ឍសិទ្ធិដែលបានចាប់ផ្តើម ហើយបានស្នើថា គំរោងផ្តោតលើការផ្តល់អំណាចដល់សហគមន៍ជនជាតិដើមភាគតិចតាមរយៈការតស៊ូមតិនិងការវិវត្តន៍អំណាច ។ គាត់បានជំរុញឱ្យបញ្ចូលអាជ្ញាធរមូលដ្ឋាន ទៅក្នុងវិធានការកសាងសមត្ថភាពពីព្រោះពួកគេ ព្រងើយកន្តើយ និងជួនកាលគំរាមអ្នកភូមិ ។

Ms Feiring បានឆ្លើយតបចំពោះការពិភាក្សានិងការពិចារណាខាងលើ :

- បញ្ហាដីធ្លីស្ថិតក្នុងចំណោមអាទិភាពដែលគំរោង ILO នឹងដោះស្រាយ។ ប៉ុន្តែនៅចំណុចនេះមិនអាចនិយាយបានថា ILO អាចរួមចំណែកដោះស្រាយ ករណីបុគ្គលដែលលើកឡើងដោយអ្នកចូលរួមបាន ឬក៏អត់ ។
- ដប់ពីរខែគឺជារយៈពេលដំបូងនៃគំរោង ប៉ុន្តែមានការសន្និដ្ឋានរួមនៅក្នុង ILO ថាបន្ទាប់ពីទទួលបានលទ្ធផលពីដំណាក់កាលដំបូងរបស់ខ្លួន គំរោងនឹងដំណើរការក្នុងទស្សនៈវិស័យរយៈពេលវែង។
- Ms Feiring បានគូសបញ្ជាក់ពីសារៈសំខាន់ដែលជនជាតដើមភាគតិចនិយាយសំរាប់ខ្លួនគេ។ ចំណុចនេះ ត្រូវការកសាងសមត្ថភាពសំរាប់អង្គការជនជាតិដើមភាគតិចក៏ដូចជាអង្គការឯទៀតដែលនឹងស្តាប់មតិនេះ ការកសាងសមត្ថភាព នឹងផ្តល់ជូនដល់អង្គការជនជាតិដើមភាគតិចក៏ដូចជាស្ថាប័ន គ្រប់ជាន់ថ្នាក់របស់រដ្ឋាភិបាល ។ អាជ្ញាធរមូលដ្ឋាន គឺជាក្រុមគោលដៅសំរាប់ការកសាងសមត្ថភាព ។
- ត្រូវការឱ្យមានមតិច្រើនទៀតពីអ្នកពាក់ព័ន្ធដើមក្បីកំណត់ទំហំភូមិសាស្ត្ររបស់គំរោង និងដើម្បីកំណត់ប្រធានបទជាអាទិភាព ។ សមាសភាពខ្លះនៃគំរោងមានការគ្របដណ្តប់ថ្នាក់ជាតិ ប៉ុន្តែគំរោងនឹងយកចិត្ត ទុកដាក់លើភាពខុសគ្នាក្នុងតំបន់ ។
- ផែនការសកម្មភាពមួយ នឹងត្រូវបានព្រាងឡើង ដោយឈរលើមូលដ្ឋានអនុសាសន៍ពីសិក្ខាសាលានេះ ។ ពង្រាងនេះនឹងត្រូវចែកជូនអ្នកចូលរួមទាំងអស់ដើម្បីផ្តល់ពត៌មានត្រឡប់អំពីគំរោងនេះនិងអំពីរបៀប ដែលរួមបញ្ចូលអនុសាសន៍ផ្សេងៗ។
- Ms Feiring បានស្នើថាត្រូវបង្កើតការផ្សព្វផ្សាយពត៌មានពាក់ព័ន្ធដ៏មានប្រសិទ្ធិភាព ជាពិសេសសំរាប់សហគមន៍ជនជាតិដើមភាគតិច ។ គាត់បានលើកទឹកចិត្តអ្នកចូលរួមទាំងអស់ឱ្យពិនិត្យតាមដាន និងកាន់កាប់គណនីភាពរបស់ ILO លើកិច្ចដែលទុនរបស់ពួកគេត្រូវបានឆ្លុះបញ្ចាំងក្នុងផែនការសកម្មភាព ។

- អ្នកតំណាងម្នាក់មកពីក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងតុលាការបានបង្ហាញថាការផ្តួចផ្តើមគំរោងដែលមានបំណងលើកស្ទួយសិទ្ធិជនជាតិដើមភាគតិច ស្របតាមរបៀបវារៈកំណែទំរង់យុត្តិធមិរបស់រដ្ឋាភិបាល ។ គាត់បានជូនដំណឹងថារដ្ឋាភិបាលមានយុទ្ធសាស្ត្រច្បាស់លាស់មួយ ហើយកាលពីសប្តាហ៍មុនរដ្ឋាភិបាលបានយល់ព្រមលើ ផែនការសកម្មភាពរយៈពេលខ្លីនិងមធ្យមមួយអំពីកំណែទំរង់យុត្តិធមិដែលផ្តល់ការការពារប្រជាជននិងជំរុញសិទ្ធិមនុស្ស ។ នៅក្នុងផែនការសកម្មភាពរបស់ខ្លួន រាជរដ្ឋាភិបាលមិនដែលព្រងើយកន្តើយនិងជនជាតិដើមភាគតិចទេ ។ ផែនការសកម្មភាពនេះ ស្ថិតនៅក្នុងចំណោមអាទិភាពនានាដើម្បីលើកកំពស់ការយល់ដឹងរបស់ ប្រជាជននិងលើកស្ទួយសិទ្ធិមនុស្ស ។ រដ្ឋាភិបាលមានគោលនយោបាយច្បាស់លាស់ ដែលមិនត្រឹមសំរាប់តែជនជាតិដើមភាគតិចទេ ប៉ុន្តែសំរាប់ប្រជាជនទាំងអស់ឱ្យបានទទួលសិទ្ធិទាំងអស់គ្នា ។ គោលនយោបាយនោះត្រូវបានអនុម័តដោយក្រុមប្រឹក្សារដ្ឋមន្ត្រី។ គាត់បាននិយាយថា គាត់រីករាយណាស់ ដែលសិក្ខាសាលាបានផ្តោតលើការអនុវត្តន៍ជាក់ស្តែងហើយថា គំរោងនេះស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ នយោបាយនេះគឺលើកស្ទួយសិទ្ធិប្រជាជនទាំងអស់ និងមានសារៈសំខាន់ក្នុងការជំរុញប្រជាធិបតេយ្យ និតិរដ្ឋនិងការបែងចែកអំណាច។
- អ្នកតំណាងសង្គមស៊ីវិលម្នាក់មកពីខេត្តពោធិសាត់ បាននិយាយថាគាត់បានសង្កេតឃើញថាការអប់រំជាភាសាខ្មែរនៅមានកំរិត ហើយគាត់បានស្នើសុំបញ្ចូលការអប់រំក្រៅប្រព័ន្ធ អំពីច្បាប់ពាក់ព័ន្ធទៅក្នុងគំរោង។
- អ្នកតំណាងម្នាក់មកពីនាយកដ្ឋានអភិវឌ្ឍសង្គមនៃក្រសួងបរិស្ថាន បានសួរថាតើគំរោងនឹងផ្តោតលើ សាសនានិងសិទ្ធិដែលពាក់ព័ន្ធឬទេ ។
- អ្នកតំណាងម្នាក់មកពីក្រសួងអប់រំបាននិយាយថាគាត់មានការបារម្ភផងដែរអំពីភាសា និងការទទួលបាន ការអប់រំនៅមានកំរិតនិងអនក្ខរភាពដែលនឹងធ្វើឱ្យមានការស្មុគ្រស្មាញចំពោះការចុះបញ្ជីកម្មសិទ្ធិដីធ្លី ។ កម្មវិធីអប់រំពីរភាសាមានស្រាប់នៅខេត្តរតនៈគីរីនិងមណ្ឌលគីរីដែលគាំទ្រដោយក្រសួងអប់រំនិង UNESCO។ សិទ្ធិទទួលបានការអប់រំសំខាន់ណាស់ មានគំនិតផ្តួចផ្តើមស្ថិតនៅស្រាប់ហើយយើងគួរសិក្សា និងចែករំលែកបទពិសោធន៍នេះ។ គាត់ក៏បាននិយាយថាគាត់យល់ព្រមលើសារៈសំខាន់នៃការកសាងសមត្ថ ភាពដែលជាកាតព្វកិច្ចរបស់ DEMD ប៉ុន្តែក្រសួងឯទៀតក៏សំខាន់ដែរដូចជា ក្រសួងអប់រំ កសិកម្ម សុខា ភិបាលនិងមហាផ្ទៃ។
- អ្នកតំណាងម្នាក់មកពី PLG រតនៈគីរីបាននិយាយថា បញ្ហាប្រឈមមុខដ៏ធ្ងន់ធ្ងរបំផុតនៅរតនៈគីរីគឺ :

1- អសន្តិសុខដោយសារកង្វះខាតដីធ្លី ។

2- ផលប៉ះពាល់ដែលនាំឱ្យបែកបាក់គ្នាអំពីសាសនាថ្មីៗដែលគំរាមកំហែងសាមគ្គីភាពសង្គម ។

3- ជនអន្តោប្រវេសន៍មកពីខាងក្រៅនិងការហូរចូលមកពីវៀតណាម ។

គាត់បានសួរថាតើ ILO រួមចំណែកយ៉ាងណាដើម្បីអនុវត្តច្បាប់ដែលមានស្រាប់ និងសួរថាតើមានយុទ្ធ សាស្រ្តណាដើម្បីឱ្យរដ្ឋាភិបាលទទួលខុសត្រូវអនុវត្តច្បាប់របស់ខ្លួន ឬ ទេ ។

Ms Feiring បានឆ្លើយតបដូចខាងក្រោម :

- នៅក្នុងថ្ងៃទីមួយអ្នកតំណាងជនជាតិដើមភាគតិច បានរកឃើញថាការអប់រំក្នុងប្រព័ន្ធ និងការបណ្តុះបណ្តាល វិជ្ជាជីវៈជាអាទិភាពសំខាន់ៗ ។ ប៉ុន្តែនេះមិនមែនជាកាតព្វកិច្ចរបស់ ILO ក្នុងការផ្តល់ការអប់រំបឋមនោះ ទេ ប៉ុន្តែ ILO អាចជួយសំរបសំរួលទំនាក់ទំនងជាមួយរដ្ឋាភិបាល ។
- ខណៈដែលការអភិរក្សភាសាមានសារៈសំខាន់ កង្វះខាតចំណេះដឹងអំពីភាសាជាតិ ក៏អាចរួមចំណែកក្នុងការធ្វើអាជីវកម្មនិងការកេងប្រវ័ញ្ចដែរ ។ គេគួរប្រកាន់យកវិធីសាស្រ្តពីរផ្លូវ ដោយផ្តោតលើភាសាកំណើតក៏ដូចជាសិទ្ធិទទួលបានការសិក្សាភាសាជាតិ ។ ចំពោះបញ្ហានេះ ជាសំខាន់ត្រូវពិនិត្យកម្មវិធីសិក្សាឡើងវិញ ហើយធានាថាគ្រូបង្រៀនយល់ដឹង និងចេះនិយាយភាសាមូលដ្ឋាន ។
- ហាក់ដូចជាមានស្ថានការណ៍តានតឹងរវាងសិទ្ធិអភិរក្សសាសនា និងសិទ្ធិជ្រើសរើសសាសនាដោយសេរី ។ គួរធានាការគោរពយ៉ាងពេញលេញចំពោះជំនឿរបស់ជនជាតិដើមភាគតិច ប៉ុន្តែក៏ត្រូវមានសេរីភាពយ៉ាង ពេញលេញផងដែរក្នុងការជ្រើសរើស ។
- ជាសំខាន់គឺរដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះប្រជាជន ។ រដ្ឋាភិបាលបានទទួលស្គាល់ថា មានគម្លាតក្នុងការអនុវត្តន៍ ចំណែកឯគំរោង ILO នឹងជួយពង្រឹង ច្បាប់តាមលទ្ធភាពដែលអាចធ្វើបាន ជាពិសេសតាម រយៈការកសាងសមត្ថភាព ។

បន្ទាប់ពីសំរាកអាហារថ្ងៃត្រង់ អ្នកចូលរួមទាំងអស់បានរៀបចំជា 5 ក្រុម តាមបញ្ហាអាទិភាពដែលបានកំណត់ក្នុង សិក្ខាសាលាថ្ងៃទីមួយ ។ សមាជិកភាពនៃក្រុម រួមមានអ្នកតំណាងជនជាតិដើមភាគតិច មន្រ្តីរដ្ឋាភិបាល អ្នកតំណាងអង្គការអន្តរជាតិ NGOs និងអ្នកតំណាងរដ្ឋាភិបាលម្ចាស់ជំនួយទ្វេ និងពហុភាគី ។ បន្ទាប់ពីការសំរាកកាហ្វេ អ្នកតំណាងក្រុមនិមួយៗបានឡើងបង្ហាញលទ្ធផលនៃការពិភាក្សាដូចខាងក្រោម :

*ការបង្ហាញរបស់ក្រុម ៖*



## ដីធ្លី

| បញ្ហា | សកម្មភាពអាទិភាព | សកម្មភាពកំពុងបន្ត | អនុសាសន៍ |
|---|---|---|---|
| គ្មានតម្លាភាពដើម្បីការពារដីទ្រព្យ សម្បត្តិរដ្ឋ (អចលនទ្រព្យ) | ១, លិខិតបទដ្ឋានពាក់ព័ន្ធការគ្រប់គ្រងដីឬអចលនវត្ថុរដ្ឋ | ក្រុមប្រឹក្សាគោលនយោបាយដីធ្លី | - ផ្តល់ការគាំទ្រ កសាងផែនទីដីរដ្ឋ<br>- ផ្តល់បច្ចេកទេស |
| ការស្គាល់អត្តសញ្ញាណដី (ដីព្រៃ ច្បាប់ព្រៃឈើ) ខ្វះភាពរលូន | ២, ខ្វះចំណាត់ថ្នាក់ដីព្រៃ ព្រំប្រ ទល់ដីដែលពាក់ព័ន្ធនឹងចំការ វិលជុំ | មានអនុក្រិត្យស្តីពីចំណាត់ថ្នាក់ដីព្រៃ "រដ្ឋបាលព្រៃឈើ" | - ត្រូវការថវិកាអនុវត្តអនុក្រិត្យ |
| មានការអូសទាញឱ្យលក់ដីសហគមន៍ | ៣, ភាពមិនស៊ីសង្វាក់នៃច្បាប់ពាក់ព័ន្ធនឹងដីធ្លី-ធនធានធម្ម ជាតិ | ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ | - ធ្វើសុខដុមនីយកម្ម (ធ្វើឱ្យរលូន) ច្បាប់ពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| មិនទានបានឱ្យអនុវត្ត ការចុះបញ្ជីដីទូទាំងប្រទេស | ៤. សហគមន៍មិនទាន់ត្រូវបានបង្កើតឡើងពេញផ្លូវច្បាប់ (ខ្វះលក្ខន្តិកៈ (អាជ្ញាធរប្រពៃណី) | ក្រសួងមហាផ្ទៃ, អាជ្ញាធរដែនដី | - អាជញាធរដែនដីគួរទទួលស្គាល់សហគមន៍បណ្តោះអាសន្ន ។<br>- សុំឱ្យអង្គការ ILO ជួយរៀបចំលក្ខន្តិកៈនិងចុះបញ្ជីសហគមន៍ |
| ផលប៉ះពាល់នៃការអនុវត្តន៏សម្បទានដីសេដ្ឋកិច្ច | ៥. ត្រូវការឱ្យមានការដាក់ចេញគោលនយោបាយអភិវឌ្ឍន៏តំបន់ខ្ពង់រាប - ជនជាតិដើម ភាគតិច | ក្រសួងអភិវឌ្ឍន៏ជនបទ និងមហាផ្ទៃ | - សហគមន៏ចូលរួមរាល់គំរោង អភិវឌ្ឍន៏<br>- សុំឱ្យ ILO ជួយទ្រទ្រង់<br>- ស្ថាប័នពាក់ពន្ធ័ចូលរួម |
| សហគមន៏ជនជាតិដើមភាគតិចមិនទាន់បង្កើតពេញផ្លូវច្បាប់ | ៦. ត្រូវការការទ្រទ្រង់ គាំទ្រផ្នែកច្បាប់ដល់សហគមន៏ | - IO<br>- NGOs | - ផ្តល់អ្នកការពារក្តី<br>- អ្នកពិគ្រោះយោបល់ច្បាប់ |
| សហគមន៏មិនយល់ច្បាស់លើសិទ្ធិពាក់ពន្ធ័នឹងដីធ្លី | ៧. ត្រូវការផ្តល់គំនិតយល់ដឹងផ្នែកច្បាប់និងសិទ្ធិលើដីធ្លី<br>- ដីសម្បទានសេដ្ឋកិច្ច | - គណៈកម្មការអភិវឌ្ឍន៏ខេត្ត ក្រុងតាមរយៈសិលា<br>- NGOs | - ពង្រីកលត្ធភាពផ្សព្វផ្សាយបណ្តុះបណ្តាល<br>- រាល់សម្បទានដីត្រូវពិគ្រោះយោ បល់<br>- EIA និង SEIA<br>- គោរពប្រពៃណី ទីសក្ការៈ |
| ខ្វះការផ្តល់ការគាំទ្រផ្នែកច្បាប់ដល់ សហគមន៏ | ៨. និទណ្ឌភាពចំពោះការពង្វាតនិងរានដីមិនស្របច្បាប់ | តុលាការ | - ត្រូវការយន្តការបណ្តឹងការពារប្រយោជន៏សាធារណៈ |

| | | | |
|---|---|---|---|
| ខ្វះលក្ខន្តិកៈផ្ទៃក្នុងសហគមន៍ពាក់ពន្ធ័នឹងការគ្រប់គ្រងនិងចាត់ចែងដី (អាជ្ញាធរព្រៃឈើ) | ៩. ផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់តំបន់ជនជាតិដើម | - សីលា<br>- ការិយាល័យរដ្ឋបាលមូលដ្ឋាន | - សហគមន៍ចូលរួម<br>- សមាហរណកម្មផែនការប្រើប្រាស់ដីសហគមន៍ក្នុងផែនការអភិវឌ្ឍន៍ ឃុំ-សង្កាត់ |
| | ១០. កង្វះប្លង់គោលកំណត់តំបន់អភិវឌ្ឍន៍ខេត្ត ក្រុង | ក្រសួងដែនដី | - ILO ផ្តល់ថវិកា និងបច្ចេកទេសសម្រាប់អនុវត្តលើ តំបន់ជនជាតិដើម |
| ខ្វះគោលនយោបាយអភិវឌ្ឍន៍តំបន់ ខ្ពង់រាបតំបន់ជនជាតិ | ១១. ត្រូវការតម្រង់ទិសអ្នកដឹកនាំឃុំ-សង្កាត់ | ក្រសួងមហាផ្ទៃ | គួរបង្កលទ្ធភាពឱ្យជនជាតិដើមគ្រប់គ្រងឃុំរបស់សហគមន៍ |
| គ្មានប្លង់ឬផែនការគោលតាមខេត្តក្រុងដែលមានជនជាតិដើមភាគតិច | | | |

- អ្នកចូលរួមម្នាក់បានកត់សម្គាល់ថាត្រូវការឱ្យមានអនុសាសន៍ខ្លាំងៗ ដើម្បីទប់ស្កាត់ផលប៉ះពាល់ជាអវិជ្ជមាននៃសម្បទានសេដ្ឋកិច្ច ។ មិនគួរផ្តល់សម្បទានដីធ្លីដោយគ្មានការជូនដំណឹងនិងការយល់ព្រមជាមុនពី ជនជាតិដើមភាគតិចទេ។

## ព្រៃឈើ សត្វ ផលផល

| | | | |
|---|---|---|---|
| - កាប់បំផ្លាញបែបអាណាធិបតេយ្យ<br>- ការកាប់ព្រៃធ្វើចំការធំៗ | - បង្កើតសហគមន៍ព្រៃឈើ<br>- ផ្សព្វផ្សាយច្បាប់ព្រៃឈើ | - រដ្ឋបាលព្រៃឈើ<br>- ក្រសួងបរិស្ថាន | - ផ្តល់ការគាំទ្រគំរោងតូចៗដែលធ្វើការងារផ្ទាល់ដល់សហគមន៍ |

| | | | |
|---|---|---|---|
| - គ្រឿវឈើ<br>- ខ្វះការយល់ដឹងពីប្រយោជន៍ព្រៃឈើ<br>- ការខ្វះការផ្សព្វផ្សាយច្បាប់<br>- ដីសម្បទានរ៉ែដែក ដាំឈើ<br>- ដុតព្រៃ ចាប់សត្វ រកដែក<br>- កាប់ដើមឈើយកសត្វ បេះផ្លែឈើ<br>ការប្រើគ្រាប់មីន អន្ទាក់ ឧបករណ៍ ខុសច្បាប់<br>- ការហូចូលរបស់អ្នកមកពីខាងក្រៅ<br>- ការវិនិយោគ<br>- ជលផល<br>- ការប្រើប្រាស់ឧបករណ៍ខុសច្បាប់<br>- ខ្វះការផ្សព្វផ្សាយច្បាប់<br>- នេសាទនៅពេលរដូវហាមឃាត់<br>- វារីអគ្គិសនី<br>- ការបំពុលដោយកាកសំណល់<br>- កាប់ព្រៃនិចទឹក | ពង្រឹងការអនុវត្តន៍ច្បាប់<br>- ពង្រឹងសមត្ថភាពនិងបច្ចេក ទេសមូលដ្ឋាន<br>- ដំណើរការ PLUP<br>- កំណត់ព្រំប្រទល់ព្រៃ<br>- គ្រប់គ្រងលិខិតស្នាមផ្លាស់ ទីលំនៅ<br>- សកម្មភាពវាយតម្លៃផលប៉ះ ពាល់<br>- រៀបចំសហគមន៍នេសាទ<br>-ផ្សព្វផ្សាយច្បាប់<br>- ពង្រឹងសមត្ថភាព ការគ្រប់ គ្រង<br>បច្ចេកទេស<br>- វាយតម្លៃផលប៉ះពាល់ | - កម្មវិធីសិលា<br>- អង្គការ<br>- សហគមន៍មូលដ្ឋាន<br>- អាជ្ញាធរដែនដី<br>- មន្ទីរដែនដី<br>- មន្ទីរបរិស្ថាន<br>- អាជ្ញាធរប្រពៃណី<br>- នាយកដ្ឋានជលផល / NGOs<br>- សហគមន៍មូលដ្ឋាន<br>- អាជ្ញាធរមូលដ្ឋាន<br>- បរិស្ថាន | - បង្កើតក្រុមពិគ្រោះយោបល់<br>នៅថ្នាក់មូលដ្ឋាន ខេត្ត ជាតិ<br>- ផ្សព្វផ្សាយច្បាប់ដល់ស្ថាប័នពាក់ ពន្ធ័<br>និងសហគមន៍មូលដ្ឋាន<br>- ផ្តល់វគ្គបណ្តុះបណ្តាលអំពីច្បាប់<br>ដល់សហគមន៍<br>- ពង្រឹងការអនុវត្តច្បាប់ ការទទួល<br>ស្គាល់ស្ថាប័នជំនាញ |

- អ្នកចូលរួមម្នាក់បង្ហាញថា អនុសាសន៍ពាក់ព័ន្ធការបង្កើតសហគមន៍ព្រៃឈើនៅខ្សោយណាស់ ។ NGOs ជាច្រើនបានផ្តួចផ្តើមឱ្យមានការបង្កើត សហគមន៍ព្រៃឈើ ប៉ុន្តែនៅខ្វះខាតការទទួលស្គាល់ពីអាជ្ញាធរព្រៃឈើ និងអនុក្រិត្យ ដើម្បីប្រតិបត្តិបទបញ្ញត្តិដែលមានស្រាប់ ។

## វប្បធម៌ ប្រពៃណី

| ការត្បាញ | បង្កើតកម្មវិធីតម្បាញ | | |
|---|---|---|---|
| ភាសា | បង្កើតសាលារៀនភាសា | | |
| តួនាទីអាជ្ញាធរប្រពៃណី | - ជំរុញឱ្យរដ្ឋាភិបាលទទួល ស្គាល់ អាជ្ញាធរប្រពៃណី និង ប្រពៃណី ដោះស្រាយទំនាស់<br>- បណ្តុះបណ្តាលអាជ្ញាធរប្រពៃណី<br>- ជ្រើសរើសអ្នកឈ្នេសវៃ និង ស្មោះត្រង់ | | សុំឱ្យ ILO បង្កើតកម្មវិធីបណ្តុះ បណ្តាលដល់ អាជ្ញាធរប្រពៃណី |
| ការបាក់បែកសាមគ្គី | រៀនវិធីសាស្ត្រសម្របសម្រួល | | ឡើ ជួយរៀបចំកម្មវិធីគាំទ្រ ដល់ការផ្សព្វផ្សាយរបៀបដោះ ស្រាយទំនាស់តាមប្រពៃណី |
| ប្រពៃណីប្រើប្រាស់ធនធានធម្មជាតិ និងព្រៃអារក្ស | ទប់ស្កាត់អ្នកខាងក្រៅ | | ជួយទប់ស្កាត់ការទន្ទ្រានពីអ្នកខាង ក្រៅ |
| ភ្លេង | បង្កើតឧបករណ៍ភ្លេង | | |

| | | | |
|---|---|---|---|
| ជំនឿ | - ផ្សព្វផ្សាយពីប្រពៃណីដល់ អាជ្ញាធរមូលដ្ឋាន<br>- ផ្សព្វផ្សាយពីទីកន្លែង<br>- ឱ្យរដ្ឋាភិបាលទទួលស្គាល់<br>- សិក្សាពីប្រវត្តិនៃជំនឿ | | |

- អ្នកចូលរួមម្នាក់បានសង្កត់ធ្ងន់អំពីតួនាទីសំខាន់របស់ជនចាស់ជរាក្នុងការស្តារប្រពៃណីឡើងវិញ ។ គួរពង្រឹងជនចាស់ជរាទាំងនោះមិនត្រូវរំសាយទេ ។ រហូតមកដល់បច្ចុប្បន្ននេះអាជ្ញាធរប្រពៃណីមិនដែល ទទួលបានការគាំទ្រពីអាជ្ញាធរមូលដ្ឋានទេ ។ អាជ្ញាធរប្រពៃណីគួរមានតួនាទីស្មើគ្នានិងអាជ្ញាធរមូលដ្ឋាន ។
- អ្នកតំណាងមកពីក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងតុលាការបង្ហាញថារដ្ឋាភិបាលបានយកចិត្តទុកដាក់ចំពោះការដោះស្រាយជម្លោះនៅក្រៅតុលាការ ។ ដោយសារតុលាការមិនអាចផ្តល់យុត្តិធម៌ ទាន់ពេលវេលាជាការល្អត្រូវប្រើស្ថាប័នប្រពៃណី ។ រដ្ឋាភិបាលបានអញ្ជើញអ្នកជំនាញការ UNDP ឱ្យជួយស្ថាប័នប្រពៃណី ក្នុងការដោះស្រាយជម្លោះហើយពួកគេបានសិក្សាឃើញថា សហគមន៍ជនជាតិដើមភាគតិចអាចរកយុត្តិធម៌ តាមប្រពៃណីរបស់ខ្លួន ។ រដ្ឋាភិបាលមានបំណងបញ្ចូលប្រព័ន្ធប្រពៃណីទាំងនេះ ។

# សុខភាព

| | | | |
|---|---|---|---|
| - ខ្វះមណ្ឌលខុខភាព ថ្នាំ គ្រូពេទ<br>- សហគន៍មិនទាន់យល់ដឹងពីសុខភាព បឋម<br>- សេវាកម្មព្យាបាលឯកជនថ្លៃ<br>- ខ្វះអាហាររូបត្ថម<br>- ខ្វះទឹកស្អាតសំរាប់ហូប<br>- ខ្វះបង្គន់អនាម័យ<br>- ជំងឺឆ្លងមានច្រើន ដូចជា គ្រុនចាញ់ គ្រុនឈាម ។ល។<br>- ខ្វះសេវាគាំពាមាតានិងទារក<br>- សេវាកម្មព្យាបាលជំងឺ មានការរើស អើងជាមួយជនជាតិដើមភាគតិច និង អ្នកក្រ<br>- ខ្វះឯកសារចងក្រងសម្រាប់មនុស្ស | - ចាំបាច់ធ្វើការសាងសង់ និង ផ្តល់ថ្នាំ និងពេទ្យ<br>- ចាំបាច់អប់រំ បណ្តុះបណ្តាល គ្រូបង្គោល និងអ្នកស្ម័គ្រចិត្ត សុខភាពភូមិ<br>- ធ្វើផ្លូវជនបទ<br>- គោលការណ៍ធានារ៉ាប់រង ផ្នែកសុខភាព និងព្យាបាល<br>- ផ្តល់បច្ចេកទេស កសិកម្មសមស្រប ដែលសហគមន៍អាច ទទួលបាន<br>- សុំស្បៀងឧបត្ថមពី WFP<br>- អណ្តូងទឹក (ស្នប់)<br>- ស្រះស្តុកទឹក<br>- អប់រំអំពីជំងឺបង្កដោយទឹក និងអនាម័យ<br>- អប់រំពីការការពារ<br>- ចាក់ថ្នាំបង្កាគ្រប់មុខ<br>- តាមដានសុខភាពផ្ទៃពោះ | - គ្មានការសង់មន្ទីពេទ្យ<br>- មានអង្គការអភិវឌ្ឍន៍ ក្រចេះ កំពង់ស្ពឺ អូរាំង បាត់ដំបង<br>- គ្មានធ្វើផ្លូវ<br>- មានអងការ LWF ADRA WFP នៅបាត់ដំបង និងកំពង់ស្ពឺ តែគ្មានទេ នៅក្រចេះ និងមណ្ឌលគីរី<br>- មានអង្គការសីលាជួយ ប៉ុន្តែមិន គ្រប់គ្រាន់<br>- មានអង្គការ/រដ្ឋបានជួយ<br>- មានថ្នាំបន្ថែមមិនគ្រប់គ្រាន់<br>- ផ្តល់ភ្នាក់ងារសុខភាពឱ្យគ្រប់ គ្រាន់ និងមធ្យោបាយ<br>- រដ្ឋមានរកមសីលធមិ ណែនាំ<br>- គ្មានអ្នកជួយគាំទ្រ<br>- គ្មានអ្នកសិក្សាស្រាវជ្រាវ/ចង ក្រង | - សុំរដ្ឋ និងអងការជួយសាងសង់ បំពាក់ឧបករណ៍ បង្រៀនឱ្យចេះប្រើ<br>- សុំមានគោលការណ៍មិនយកលុយ ចំពោះអ្នកក្រ<br>- ជួយធ្វើផ្លូវភ្ជាប់មណ្ឌលសុខភាព និងជនបទ<br>- បណ្តុះបណ្តាលកសិកម្ម<br>- ផ្តល់ពូជ ដំណាំ សត្វ<br>- WFP / MCH (កម្មវិធីសុខភាព ម្តាយ និងទារក)<br>- សិក្សាទឹកក្រោមដី<br>- រដ្ឋាភិបាល និងឯកជនជួយបន្ថែម ទឹកស្រះ អណ្តូង<br>- ផ្តល់ថ្នាំការពារគ្រុនចាញ់<br>- ផ្លស់ប្តូរទម្លាប់<br>- បន្តជួយផ្តល់មុង |

| | | | |
|---|---|---|---|
| ជំនាន់ក្រោយ | ការលូតលាស់របស់ទារក<br>- សិក្សា ស្រាវជ្រាវ និងចងក្រង<br>- បណ្តុះបណ្តាលបន្ថែម<br>- ចងក្រងបណ្តាញថ្នាំបុរាណ | - បណ្តុះបណ្តាលក្មេងជំនាន់ក្រោយ បន្តការងារនេះ | - UNICEF Rតូវចុះជួយពិនិត្យដល់ ជនបទដាច់ស្រយ៉ាល<br>- ជួយភូមិបង្កើតថ្មី ដែលគ្មានក្នុង បញ្ជីរដ្ឋបាល<br>- សុំឱ្យខេត្ត/ក្រសួងសុខាភិបាល ចុះណែនាំ ពង្រឹងក្រមសីលធម៌<br>- ត្រូវមានតំណាងជនជាតិដើមភាគ តិចចូលក្នុងគណៈកម្មការទ្រទ្រង់ មណ្ឌល សុខភាព<br>- ប្រជុំជាប្រចាំខែ ត្រីមាស ឆ្នាំ<br>- ក្រសួងសុខាភិបាល បណ្តុះ បណ្តាលបន្ថែម ដល់គ្រូបុរាណ<br>- ចងក្រងឯកសារទុកក្នុងសហគមន៍<br>- បង្កើតបណ្តាញគ្រូបុរាណ ផ្លាស់ប្តូរ បទពិសោធន៍ |

# អប់រំ បណ្ដុះបណ្ដាល វិជ្ជាជីវៈ

| | | | |
|---|---|---|---|
| ១. ខ្វះគ្រូបង្រៀនចំណេះដឹងទូទៅ<br>២, ខ្វះថ្នាក់អក្ខរកម្មភាសា ព័រ កួយ ជង សួយ កាចក់<br>៣, ខ្វះការបណ្ដុះបណ្ដាលគ្រូអក្ខរកម្ម ពីរ ភាសា<br>៤, ខ្វះសម្ភារៈសិក្សា<br>៥, ខ្វះបណ្ណាល័យចល័ត<br>៦, ខ្វះការបណ្ដុះបណ្ដាល<br>- តម្បាញ<br>- ចម្លាក់<br>- ជាងកាត់ដេរ<br>- ជាងដំកាំមបិត ពូថៅ<br>- បច្ចេកទេសកសិកម្ម ចិញ្ចឹមសត្វ ដាំបន្លែ ដំណាំ<br>៧, ខ្វះពិមានទូទៅ<br>៨, ខ្វះប្រពន្ធ័សំណេជាអក្សរខ្មែរ សម្លេងជនជាតិដើម | ១, សិក្សា សាវជ្រាវរៀបចំប្រ ពន្ធ័ សំណេជាអក្សរសម្លេង ជនជាតិ<br>២, កសាងកម្មវិធីសិក្សាដោយមានការ ចូលរួមពីសហគមន៏<br>៣, បណ្ដុះបណ្ដាលគ្រូអក្ខរកម្ម ពីរ ភាសា<br>៤, បង្កើតថ្នាក់អក្ខរកម្ម ពីរ ភាសា<br>៥, បង្កើត បណ្ណាល័យចល័ត<br>៦, បណ្ដុះបណ្ដាល បច្ចេកទេស កសិកម្ម ចិញ្ចឹមសត្វ ដាំបន្លែ ដំណាំ<br>៧, ផ្សព្វផ្សាយពិតមានឱ្យបាន ទូលំទូលាយដល់សហគមន៏ជន ជាតិដើមភាគតិច<br>៨, បណ្ដុះបណ្ដាលវិជ្ជាជីវៈតម្រូវ តាមមូលដ្ឋាន | ១, អប់រំក្រៅប្រពន្ធ័<br><br>២, មិនទាន់មាន<br><br>៣, មិនទាន់មាន | - សុំឱ្យស្ថាប័នអង្គារពាក់ពន្ធ័នានា ជាមួយសហការរៀបចំគំរោងការ បង្រៀន<br>- សុំមានការសហការជាមួយ ចាស់ទុំ អាជ្ញាធរមូលដ្ឋាន ស្ថាប័ន ពាក់ពន្ធ័ និងអង្គការសង្គមស៊ីវិល គាំទ្រលើ គំរោងអប់រំ និងបណ្ដុះបណ្ដាលតាម សហគមន៏ |

## *សុន្ទរកថាបិទដោយ Ms Birgitte Feiring ជាប្រធានទីប្រឹក្សាបច្ចេកទេសរបស់ ILO, PRO 169*

ក្នុងពិធីបិទ Ms Feiring បានថ្លែងអំណរគុណអ្នកចូលរួមទាំងអស់ដែលបានរួមចំណែក និងបានប្រឹងប្រែងធ្វើឱ្យ សិក្ខាសាលាបានទទួលជោគជ័យ ។ គាត់បានកត់សំគាល់ថា គាត់រីករាយណាស់ដោយបានឮការប្តេជ្ញាចិត្តពីអ្នកតំណាងរដ្ឋាភិបាលជាច្រើន ក្នុងការលើកស្ទួយសិទ្ធិជនជាតិដើមភាគតិច ។ គាត់បានថ្លែងថា គាត់ទន្ទឹងរង់ចាំដោយរីករាយ ដើម្បីធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ និងអនុវត្តគោលនយោបាយ និងច្បាប់ដែលពាក់ព័ន្ធនានា ។ គាត់បានថ្លែងទៀតថា គាត់បានរៀនសូត្រយ៉ាងច្រើននៅថ្ងៃនេះ អំពីកង្វល់របស់ជនជាតិដើមភាគតិចនៅកម្ពុជា និងបានថ្លែងអំណរ សាទរជាពិសេសស្ត្រីដែលបានចូលរួមយ៉ាងសកម្ម ។

Ms Feiring បានសន្យាថា ILO នឹងប្រឹងប្រែងធ្វើការងារស្វែងរកភាព ជាដៃគូជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីពាំនាំផលប្រយោជន៍ដែលមានផលប៉ះពាល់ដោយផ្ទាល់នៅក្នុងសហគមន៍ ។ ត្រូវបង្កើតផែនការសកម្មភាព មួយនិងទំនាក់ទំនងជាមួយដៃគូជាមុនសិនមុនពេលចាប់ផ្តើមអនុវត្ត ។

គាត់បានថ្លែងថា ឥឡូវនេះគំរោងនឹងវិភាគលទ្ធផលសិក្ខាសាលានិងកំណត់វិស័យណាមួយដែល ILO អាចបន្ថែមតំលៃ ។ គំរោងនឹងបង្កើតផែនការសកម្មភាពមួយ ដែលនឹងឆ្លុះបញ្ចាំងអនុសាសន៍នៃសិក្ខាសាលានេះ ។ គាត់បានបង្ហាញថា ទំនាក់ទំនងជាមួយគំរោងឯទៀតរបស់ ILO បានកំណត់រួចហើយ ដូចជានៅក្នុងវិស័យសុខាភិបាល និងការផលិតសិប្បកម្មជាមួយសហការីរបស់ ILO គំរោងនឹងស្វែងរកវិធីគៀងគរការរួមផ្សំគ្នា ដែលមានសក្តានុពល ។

Ms Feiring ក៏បានបញ្ជាក់ពីសារៈសំខាន់នៃទំនាក់ទំនងនិងការផ្តល់ពតិមានឥតឈប់ឈរ ។ គាត់បានលើកទឹកចិត្តអ្នកចូលរួមទាំងអស់ឱ្យចែករំលែកមតិ និងការរិះគន់នៅដំណាក់កាលណាមួយនៃគំរោង និងប្រកាន់ខ្ជាប់ការទទួល ខុសត្រូវរបស់ ILO សំរាប់ការអនុវត្តន៍ ។

ជាចុងបញ្ចប់ Ms Feiring បានបង្ហាញនូវការពេញចិត្តរបស់គាត់ចំពោះលទ្ធផលសិក្ខាសាលា និងសម្តែងពីការប្តេជ្ញាចិត្តរបស់ ~ឡ ក្នុងការប្រែក្លាយពាក្យសំដីឱ្យទៅជាការអនុវត្តន៍ ។ គាត់បានសង្កត់ធ្ងន់ថា នេះគឺជាការចាប់ផ្តើម មិនមែនជាចុងបញ្ចប់នៃដំណើរការទេ។

## *សុន្ទរកថាបិទដោយ ឯកឧត្តម Sos Mou Sine ជាអនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍជនបទ*

ឯកឧត្តម Sos Mou Sine បានថ្លែងថាគាត់រីករាយនិងចូលរួមក្នុងសិក្ខាសាលាសម្ពោធគំរោងនេះ ។ គាត់បានសម្តែងទស្សនៈថា សិក្ខាសាលាបានបង្កើតជំហាន ដ៏សំខាន់ដើម្បីកែលំអរស្ថានភាពជនជាតិដើមភាគភាគតិចនៅកម្ពុជា ហើយវិវឌ្ឍនភាពច្រើនទៀតនឹងត្រូវបានបង្ហាញឡើងក្នុង អំឡុងពេលអនុវត្តគំរោង ។ គាត់បានសំដែងនូវការពេញចិត្តរបស់គាត់ និងដំណើរការសិក្ខាសាលាដែលបានឆ្លុះបញ្ចាំងនូវគោលការណ៏ចូលរួមនិងពិគ្រោះយោបល់ជាបទដ្ឋានគ្រិះ ដែលរាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្ត ដើម្បីកែលំអរក្នុងការបង្កើតនិងការអនុវត្តន៏ច្បាប់និងគោលនយោបាយដែលប៉ះពាល់ដល់ជនជាតិដើមភាគតិចនៅក្នុងប្រទេស ។

ឯកឧត្តម Sos Mou Sine បានបញ្ជាក់ថាសិក្ខាសាលានឹងពង្រឹងដៃគូដែលមានស្រាប់ និងបង្កើតដៃគូថ្មីៗ រវាងភាគីពាក់ព័ន្ធដែលនឹងសំរបសំរួលការអភិវឌ្ឍន៏ និងការអនុវត្តន៏ច្បាប់ និងគោលនយោបាយ ដែលបញ្ចូលសិទ្ធិតំរូវការ និងអាទិភាពរបស់ជនជាតិដើមភាគតិចនៅកម្ពុជា ។ គាត់បានថ្លែងថាគាត់ទន្ទឹងរង់ចាំដោយរីករាយ ដើម្បីឃើញផែនការសកម្មភាពមួយដែលតាក់តែងឡើងដោយឈរលើមូលដ្ឋាន អនុសាសន៏នៃសិក្ខាសាលានេះហើយគាត់ នឹងរួមចំណែកជំរុញឱ្យអនុវត្តផែនការសកម្មភាពនេះ ។

ឯកឧត្តម Sos Mou Sine បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តកែលំអរស្ថានភាពនិងអភិវឌ្ឍសិទ្ធិជនជាតិដើមភាគតិច ។ គាត់បានសង្កត់ធ្ងន់ថាក្រសួងអភិវឌ្ឍជនបទ ដែលទទួលបានអាណត្តិដើម្បីអភិវឌ្ឍជនជាតិដើមភាគតិច គាំទ្រយ៉ាងពេញទំហឹងនូវដំណើរការធ្វើបច្ចុប្បន្នភាពនៃ " គោលនយោបាយទូទៅដើម្បីអភិវឌ្ឍប្រជាជនតំបន់ភ្នំ " ហើយក្រសួងបានប្តេជ្ញាចិត្តធ្វើតាមការអនុម័តរបស់ខ្លួន និងការអនុវត្តន៏តាមរយៈរាជរដ្ឋាភិបាលកម្ពុជាមុនពេលបិទសិក្ខាសាលា និងថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់ដែលបានរួមចំណែក ឯកឧត្តម Sos Mou Sine បានថ្លែងថាគាត់មានជំនឿថា លទ្ធផលដែលទទួលបានតាមរយៈសិក្ខាសាលានេះ និងត្រូវបានរក្សាទុក ដើម្បីធានាថាគោលបំណងនេះអាចត្រូវបានសំរេចឡើង ។

# បញ្ជីវត្តមាន

## សិក្ខាសាលា ៥ និង ៦ ឧសភា ២០០៥

| លរ | ឈ្មោះ | ភេទ | ជនជាតិ | តួនាទី | ខេត្ត/ស្ថាប័ន | ទីតាំងការងារ | ហត្ថលេខា |
|---|---|---|---|---|---|---|---|
| ១ | អៀម អឿន | ប | ខ្មែរ | អនុប្រធានមន្ទីរអភិវឌ្ឍ ជនបទ | រតនៈគីរី | | |
| ២ | ប៉ែត ភក្ត្រា | ប | ខ្មែរ | អ្នកសំរបសំរួល Plup | មណ្ឌលគីរី | | |
| ៣ | វន់ ភានី | ស | ខ្មែរ | អនុប្រធាននាយកដ្ឋាន | ក្រសួង ជនស | ភ្នំពេញ | |
| ៤ | ឡេា ប៊ុណ្ណាត | ប | ខ្មែរ | ប្រធានគំរោង | LWF-Oral | Oral | |
| ៥ | ចាប គីមជុន | ប | ខ្មែរ | អនុប្រធាន | អប់រំក្រៅប្រព័ន្ធ | ភ្នំពេញ | |
| ៦ | បេង រ៉ែន | ស | ខ្មែរ | ប្រធានមន្ទីរ | ខេត្តមណ្ឌលគីរី | | |
| ៧ | ឃន សុខខេង | ប | ខ្មែរ | អនុប្រធានមន្ទីរ | រៀបចំដែនដី ក្រចេះ | | |
| ៨ | ហ៊ី ចន្ថា | ប | ខ្មែរ | អនុប្រធានមន្ទីរ | រៀបចំដែនដី ស្ទឹងត្រែង | | |
| ៩ | សុត សឿង | ប | ខ្មែរ | អនុប្រធាននាយកដ្ឋាន | អភិវឌ្ឍន៏ជនបទ | ភ្នំពេញ | |
| ១០ | វ៉ិត វណ្ណារ៉ា | ប | ខ្មែរ | ប្រធានការិយាល័យ | នាយកដ្ឋានអភិវឌ្ឍន៏<br>ជនជាតិភាគតិច /MRD | ភ្នំពេញ | |
| ១១ | អ៊ឹម ម៉ារ៉ាឌី | ស | ខ្មែរ | មន្ត្រីរដ្ឋបាលព្រៃឈើ | រដ្ឋបាលព្រៃឈើ | ភ្នំពេញ | |
| ១២ | ហេង បូរ៉ានី | ស | ខ្មែរ | មន្ត្រីរដ្ឋបាលព្រៃឈើ | រដ្ឋបាលព្រៃឈើ | ភ្នំពេញ | |
| ១៣ | រាម ច័ន្ទវណ្ណា | ប | ខ្មែរ | ប្រធានការិយាល័យ | MIME | ភ្នំពេញ | |
| ១៤ | ហ៊ុន ធីរិទ្ធ | ប | ខ្មែរ | អ្នកស្រាវជ្រាវ | CAS | ភ្នំពេញ | |
| ១៥ | សរ កុសល | ប | ខ្មែរ | អ្នកស្រាវជ្រាវ | MoB | ភ្នំពេញ | |
| ១៦ | បណ្ឌិត ប៉ែន ដារេត | ប | ខ្មែរ | រដ្ឋលេខាធិការ | ទីស្តីការគណៈរដ្ឋមន្ត្រី | ភ្នំពេញ | |
| ១៧ | យ៉ត ប៊ុននី | ប | ខ្មែរ | និសិត្ស | DMC (RUPP) | DMC (RUPP) | |
| ១៨ | Phan Sin | M | UNDP | UNDP Staff | UNDP | Phnom Penh | |
| ១៩ | Raquel Frigouyan | F | UNDP | | Farvvian | Phnom Penh | |
| ២០ | Kong Rady | M | UNDP | | Cambodia | Phnom Penh | |
| ២១ | Narin Sok | M | UNDP | UNDP Staff | | PNP | |
| ២២ | Kit Touch | M | CLEC | P.O | Cambodia | PNP | |
| ២៣ | Peter Surifr | M | SADO | PO | USA | | |
| ២៤ | Ek Yotein | M | NGO Forum | PO | Cambodia | PNP | |
| ២៥ | Phay Sok Kheng | M | COJ (COM) | | | PNP | 012 933 351 |
| ២៦ | Kristina Chhim | F | German | Senior Research Coordinator | CAS | | |
| ២៧ | Phea Phalla | F | Cambodian | Research Advisor | PLG / Seila | Ratana Kiri | |
| ២៨ | Hean Sokhom | | | | CAS | | |
| ២៩ | Kong Mouk | | Government | Head of Department | Council of Minute | | |
| ៣០ | Cheam Mony | | Cambodi an | Team Leader | WWF | PNP | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣១ | Buth Kong Kea | M | Cambodian | Deputy Director | IHF | PNP | |
| ៣២ | Janrmt Marillan | M | Frech | Human Rights Officer | OHCHR | PNP | |
| ៣៣ | Mefan Maclanes | F | Scotland | Nomad RSI | | Mondulkiri | |
| ៣៤ | Tom Evans | M | UK | WCS | | MDK | |
| ៣៥ | Chou Vireak | F | Cambodian | Lawyer | CLEC | PNP | |
| ៣៦ | Keat Bophal | F | Cambodian | HRS Worker | UNCOHCHR | PNP | |
| ៣៧ | Khatija Thomas | F | Australian | Legal Advisor | CLEC | PNP | |
| ៣៨ | Daniel Adler | M | Australian | Project Manager | World Bank | PNP | |
| ៣៩ | សឿន សារឿន | ស | ស្ទៀង | សហគមន៍ | ស្រីសន្តិភាព និង បរិស្ថាន | ក្រចេះ | |
| ៤០ | អ៊ឹម សុធី | ប | ព័រ | តំណាងសហគមន៍ | សហគមន៍អភិវឌ្ឍន៍ ជនបទ | ព្រះវិហារ | |
| ៤១ | យ៉េន យ៉ាត | ស | ព្រៅ | តំណាងសហគមន៍ | ស្រីសន្តិភាព | ស្ទឹងត្រែង | |
| ៤២ | យ៉ន សាអ៊ីន | ស | កួយ | តំណាងសហគមន៍ | ប្រជាពលរដ្ឋ | ក្រចេះ | |
| ៤៣ | ព្រៀាន បូរ៉ា | ស | ភ្នង | តំណាងសហគមន៍ | គណៈកម្មការ CF | មណ្ឌលគីរី | |
| ៤៤ | ស្រើស មឿង | ប | ភ្នង | តំណាងសហគមន៍ | សន្តិភាពដើម្បីបរិស្ថាន | មណ្ឌលគីរី | |
| ៤៥ | វ៉ៃក ណម | ស | កួយ | តំណាងសហគមន៍ | ប្រជាពលរដ្ឋ | សៀមរាប | |
| ៤៦ | ឈ្លៀម ឈៀន | ប | ជង | តំណាង | ប្រជាពលរដ្ឋ | កោះកុង | |
| ៤៧ | អ៊ុយ យ៉េត | ប | ព័រ | តំណាង | ប្រជាពលរដ្ឋ | ពោធិសាត់ | |
| ៤៨ | កង ចយ | ប | ជង | តំណាង | ប្រជាពលរដ្ឋ | កោះកុង | |
| ៤៩ | ជី បូរ៉េត | ប | កួយ | ប្រធានអង្គការ CDA | | បន្ទាយមានជ័យ | |
| ៥០ | យួន ឌី | ប | កួយ | តំណាងសហគមន៍ | សហគមន៍ | ស្ទឹងត្រែង | |
| ៥១ | ទីង យ៉ាំមី | ប | តុំពួន | តំណាងសហគមន៍ | សហគមន៍ | រតនៈគីរី | |
| ៥២ | រថ ហ្លើច | ប | ច្រាយ | តំណាង | សហគមន៍ | រតនៈគីរី | |
| ៥៣ | ហាន កំប៉ល | ស | គ្រឹង | តំណាង | សហគមន៍ | រតនៈគីរី | |
| ៥៤ | ព្រី ខាំសាញ់ | ប | ព្រៅ | តំណាង | សហគមន៍ខ្មែរលើ | រតនៈគីរី | |
| ៥៥ | ប៉ោ លេ | ស | ភ្នង | តំណាង | គណៈកម្មការសហគមន៍ | មណ្ឌលគីរី | |
| ៥៦ | សុខ សុភន | ប | ទំពួន | តំណាងសហគមន៍ | បុគ្គលិកគំរោង RNSP | រតនៈគីរី | |
| ៥៧ | ឡូវ ប៊ុនលៀង | ស | ព័រ | នាយកប្រតិបត្តិ | DPKS | ពោធិសាត់ | |
| ៥៨ | លុង សិទ្ធ | ប | កួយ | ប្រធានសហគមន៍ | សហគមន៍ | ឧត្តរមានជ័យ | |
| ៥៩ | ព្រុំ យូ | ប | កួយ | ប្រធានសហគមន៍ | សហគមន៍ | កំពង់ធំ | |
| ៦០ | ណាំ នី | ប | ព័រ | តំណាងសហគមន៍ | សហគមន៍ | បាត់ដំបង | |
| ៦១ | ស្រី ឡេង | ប | កួយ | តំណាងសហគមន៍ | សហគមន៍ | ព្រះវិហារ | |
| ៦២ | ទេព ទឹម | ស | កួយ | តំណាងសហគមន៍ | សហគមន៍ | ព្រះវិហារ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦៣ | ប៉េក សាវ | ស | ស្ទូយ | តំណាងសហគមន៍ | សហគមន៍ | កំពង់ស្ពឺ | |
| ៦៤ | ភី តេរ | ប | ភ្នង | តំណាងសហគមន៍ | សហគមន៍ | មណ្ឌលគីរី | |
| ៦៥ | ផល់ ណឿន | ប | ស្ទូស | តំណាងសហគមន៍ | សហគមន៍ | កំពង់ស្ពឺ | |
| ៦៦ | សរ កុសល | ប | ខ្មែរ | មន្ត្រីក្រសួងបរិស្ថាន | | ភ្នំពេញ | |
| ៦៧ | អ៊ឹម ម៉ារ៉ាឌី | ស | ខ្មែរ | មន្ត្រីរដ្ឋបាលព្រៃឈើ | | ភ្នំពេញ | |
| ៦៨ | ហេង បូរ៉ានី | ស | ខ្មែរ | មន្ត្រីរដ្ឋបាលព្រៃឈើ | | ភ្នំពេញ | |
| ៦៩ | ប៉ែត ភត្រា | ប | ខ្មែរ | អ្នកសំរបសំរួល Plup | (WCS) | មណ្ឌលគីរី | |
| ៧០ | Khatija Thomas | F | Australian | Legal Advisor | CLEC | PNP | |
| ៧១ | អ៊ុច គីមណាលី | ស | ខ្មែរ | នាយិកា | SSP | | |